ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..................សហវ.......

## សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

❋❋❋✧❋❋❋

### ១. សេចក្តីផ្តើម

**១.** នៅក្រោមបរិការណ៍នៃសុខសន្តិភាព, ឯករាជ្យជាតិ និងស្ថិរភាពនយោបាយ ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវការអភិវឌ្ឍឥតឈប់ឈរ ថែមទាំងបានផ្លាស់ប្តូរមុខមាត់ថ្មី ដោយវិវត្តន៍ខ្លួនទៅជាប្រទេសចំណូលមធ្យមកម្រិតទាប ។ សមិទ្ធផលទាំងនេះ បាននាំមកនូវមោទនភាពជាតិ សេចក្តីទុកចិត្ត និងសេចក្តីសង្ឃឹមយ៉ាងមុតមាំសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិ ក្នុងការបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាប្រកបដោយគុណភាព ។ ការណ៍នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈគ្រប់កម្រិត ក្នុងការដោះស្រាយរាល់បញ្ហាប្រឈម និងហានិភ័យក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏ដូចជាបំពេញសេចក្តីត្រូវការរបស់ប្រជាជនព្រមទាំងធានាសន្តិសុខ និងសុខុមាលភាពសង្គម សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ឈរលើក្របខ័ណ្ឌគោលនយោបាយឈានទៅសម្រេចបាន **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៦ នៃរដ្ឋសភា កំពុងរៀបចំ និងគ្រោងដាក់ចេញនូវកម្មវិធី និងវិធានការគោលនយោបាយមុតស្រួចនានា ក៏ដូចជាក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ដើម្បីឱ្យកម្ពុជាសម្រេចបានឯករាជ្យភាពសេដ្ឋកិច្ច ព្រមទាំងចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ។

**២.** សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនលើសពីការរំពឹងទុករហូតដល់ ៧,៥% ក្នុងឆ្នាំ ២០១៨ ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ស្របពេលដែលអតិផរណាក៏ស្ថិតនៅក្នុងកម្រិតទាបអាចគ្រប់គ្រងបានក្នុងអត្រាប្រមាណជា ២,៥% ទោះបីឆ្នាំ ២០១៨ ជាឆ្នាំបោះឆ្នោតជាតិក៏ដោយ ។ កំណើននេះបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យ ដូចជា ការវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស, ការប្រើប្រាស់ក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ ។ ការណ៍នេះសបញ្ជាក់ឱ្យឃើញពីការកើនឡើងនូវទំនុកចិត្តរបស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស ចំពោះភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ទោះបីជាសេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងហានិភ័យកាន់តែច្រើនជាងមុន ។

**៣.** សម្រាប់ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៨ ចំណូលចរន្តមានកំណើនប្រមាណ ២០,៤% ដែលស្មើនឹង ២១,៩៦% នៃ ផសស ដែលក្នុងនោះចំណូលសារពើពន្ធបានកើនឡើងប្រមាណ ២២,០% និង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

ចំណូលមិនមែនសារពើពន្ធមានកំណើនយឺតត្រឹម ១០,៤% ។ លទ្ធផលល្អប្រសើរនៃចំណូលសារពើពន្ធនេះ បានមកពីកំណើនខ្ពស់លើសការរំពឹងទុកនៃចំណូលដែលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលមានកំណើនប្រមាណ ៣២,៤% ខណៈដែលកំណើនចំណូលដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារមានកំណើនយឺតត្រឹម ១២,០% ។ ទន្ទឹមនេះ ថវិកាចំណាយសរុបបានកើនឡើងប្រមាណ ១៤,៥% ដែលស្មើនឹង ២៤,៣៩% នៃ ផសស ក្នុងនោះចំណាយបន្ទុកបុគ្គលិកស្មើនឹងប្រមាណ ៨,៤១% នៃ ផសស ខណៈចំណាយក្រៅបន្ទុកបុគ្គលិកស្មើនឹង ៧,៧៦% នៃ ផសស ។ ដូចនេះ អតិរេកចរន្តអាចសម្រេចបានក្នុងកម្រិត ៥,៨០% នៃ ផសស និងឱនភាពថវិកាសរុបស្ថិតក្នុងកម្រិត ២,២៣% នៃ ផសស ។

៤. សមិទ្ធផលសេដ្ឋកិច្ចដ៏គួរឱ្យកោតសរសើរក្នុងឆ្នាំ ២០១៨ នេះ អាចសម្រេចទៅបានដោយសារកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រឹមត្រូវ និងសមស្រប ដែលជំរុញដល់ការវិនិយោគ និងភាពផុសផុលនៃសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យ ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុវត្តនូវគោលនយោបាយសារពើពន្ធ រួមមានការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារមូលដ្ឋាន និងការបន្ធូរបន្ថយបន្ទុកពន្ធនិងកែសម្រួលថ្លៃលក់ប្រេងឥន្ធនៈនៅលើទីផ្សារ ។ ទន្ទឹមនេះ គោលនយោបាយរូបិយវត្ថុ ត្រូវបានអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្ន និងមានសង្គតិភាពជាមួយនឹងគោលនយោបាយសារពើពន្ធ តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយផ្អែកតាមតម្រូវការ និងស្របតាមមូលដ្ឋានសេដ្ឋកិច្ច ។ ជាមួយគ្នានេះដែរ វិធានការគោលនយោបាយមួយចំនួនទៀតត្រូវបានដាក់ចេញ រួមមានការលុបភាសី និងការបង្កើនភាពប្រកួតប្រជែងក្នុងអាជីវកម្មសត្តឃាតដ្ឋាន ដើម្បីរួមចំណែកក្នុងការធានាស្ថិរភាពថ្លៃ និងជំរុញកំណើនសេដ្ឋកិច្ចផងដែរ ។

៥. យោងតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ ២០១៨ ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតទាបជាងឆ្នាំ ២០១៧ បន្តិច ពោលគឺក្នុងអត្រា ៣,៧% ដោយសារឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន ដែលបានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចសកល ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មរបស់ប្រទេសទាំងពីរនេះ ។ ក្រៅពីនេះ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៅបណ្តាប្រទេសអភិវឌ្ឍន៍ បានបង្កឱ្យមានលំហូរមូលធនចេញពីប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងកំពុងអភិវឌ្ឍន៍ (emerging and developing economies) ។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចសហរដ្ឋអាមេរិកត្រូវបានប៉ាន់ស្មានថាសម្រេចបានអត្រាកំណើនខ្ពស់ជាងការរំពឹងទុកប្រមាណជា ២,៩% ដោយសារការកើនឡើងនៃការប្រើប្រាស់ និងការវិនិយោគក្នុងស្រុក ខណៈដែលកំណើនសេដ្ឋកិច្ចចិនបានថមថយមកប្រមាណ ៦,៦% ដោយសារផលប៉ះពាល់នៃសង្គ្រាមពាណិជ្ជកម្ម ដែលបានដាក់សម្ពាធលើផលិតកម្មក្នុងស្រុក និងការនាំចេញ ។ ក្នុងឆ្នាំ ២០១៩ និង ២០២០ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងមានកំណើនទាបជាងឆ្នាំ ២០១៨ មកក្នុងរង្វង់ ៣,៥% និង ៣,៦% ដោយសារការរំពឹងទុកនៃការថមថយទំនុកចិត្តវិនិយោគ, ការបង្អាក់នៃច្រវ៉ាក់ផលិតកម្មសកល និងការកើនយឺត

នៃផលិតភាពផលិតកម្មជារួម ដែលបណ្ដាលមកពីសង្គ្រាមពាណិជ្ជកម្ម និងភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មសកល និងការថយចុះជាងការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចចិន ។

**៦.** ការកើនឡើងនូវភាពមិនប្រាកដប្រជា និងបញ្ហាប្រឈមរបស់សេដ្ឋកិច្ចសកល ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែងាយរងគ្រោះ ។ ហានិភ័យទាំងនោះរួមមាន៖

(១). ភាពមិនប្រាកដប្រជានៃការដកការអនុគ្រោះពន្ធលើគ្រប់មុខទំនិញលើកលែងសព្វាវុធ (EBA) ដោយសហភាពអឺរ៉ុប;

(២). សង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន;

(៣). ការបន្ដរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍;

(៤). ភាពមិនប្រាកដប្រជានៃគោលនយោបាយរបស់សហរដ្ឋអាមេរិក;

(៥). ការថមថយជាងការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចចិន;

(៦). បញ្ហាពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ, ភេរវកម្ម និងសន្ដិសុខសកលជាដើម និង

(៧). ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។

ទន្ទឹមនេះ កម្ពុជាក៏ជួបនូវបញ្ហាប្រឈមក្នុងស្រុកមួយចំនួនផងដែររួមមាន៖

(១). មូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត និងល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ចមានភាពយឺតយ៉ាវ;

(២). ថ្លៃអគ្គិសនីនៅមានកម្រិតខ្ពស់បើប្រៀបធៀបជាមួយប្រទេសជិតខាង និងអស្ថិរភាពនៃការផ្គត់ផ្គង់ ទោះបីជាថ្លៃនេះបានធ្លាក់ចុះបន្តិចក្នុងឆ្នាំកន្លងមកក៏ដោយ;

(៣). ភាពនៅទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងប្រព័ន្ធឡូជីស្ទីក;

(៤). កំណើនផលិតភាពពលកម្មទាប និងកង្វះពលកម្មជំនាញ;

(៥). សម្ពាធនៃការកើនឡើងប្រាក់ឈ្នួល;

(៦). នីតិវិធីស្មុគស្មាញ និងកម្រៃសេវាក្រៅផ្លូវការនៅមានកម្រិតខ្ពស់សម្រាប់ការធ្វើធុរកិច្ច និង

(៧). កំណើនឆាប់រហ័សនៃឥណទានក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ ។

**៧.** ជារួម ក្នុងរយៈពេលមធ្យម ហានិភ័យចំពោះសេដ្ឋកិច្ចកម្ពុជានឹងកាន់តែមានទំហំធំ ជាពិសេសលទ្ធភាពនៃការដក EBA ដែលអាចធ្វើឱ្យបាត់បង់ការងារ និងប៉ះពាល់ជាអវិជ្ជមានលើវិស័យផ្សេងៗ ដូច្នេះកម្ពុជាចាំបាច់ត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការដាក់ចេញ និងអនុវត្តនូវវិធានការអន្តរាគមន៍សមស្របឱ្យបានទាន់ពេលវេលា, ចេញជាផ្លែផ្កា និងប្រកបដោយឆន្ទៈនយោបាយខ្ពស់ ក្នុងគោលដៅធានាបន្តចលនការនៃការទ្រទ្រង់កំណើនសេដ្ឋកិច្ចរឹងមាំ ពិសេសតាមរយៈការអនុវត្តគោលនយោបាយបញ្ច្រាសវដ្តធុរកិច្ច (countercyclical fiscal policy) ប្រកបដោយភាពប្រុងប្រយ័ត្ន, ការពន្លឿនការកែទម្រង់ជារចនាសម្ព័ន្ធ, ការគ្រប់គ្រងហានិភ័យក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកលលោក និងសេដ្ឋកិច្ចកម្ពុជា ព្រមទាំងការពន្លឿនការកសាងនិងពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ។ ទន្ទឹមនេះ ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី ៤ កម្ពុជានឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ

សេដ្ឋកិច្ចឌីជីថល ដើម្បីចាប់យកសក្តានុពលនៃការផ្លាស់ប្តូរបច្ចេកវិទ្យាព័ត៌មាន ក្នុងការចូលរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

## ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**៨.** សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថាអាចសម្រេចបានកំណើនខ្ពស់ជាងការរំពឹងទុករហូតដល់ទៅ ៧,៥% ក្នុងឆ្នាំ ២០១៨ ដែលគាំទ្រដោយកំណើនខ្ពស់លើសពីការប៉ាន់ស្មាននៃវិស័យកាត់ដេរ, កំណើនរឹងមាំនៃវិស័យសំណង់ និងវិស័យអចលនទ្រព្យ ស្របនឹងកំណើនល្អប្រសើរនៃវិស័យលក់ដុំ-លក់រាយ និងវិស័យដឹកជញ្ជូន និងគមនាគមន៍ ។ ក្នុងឆ្នាំ ២០១៩ សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងនៅបន្តកំណើនរឹងមាំក្នុងរង្វង់ប្រមាណ ៧,១% ដែលភាគច្រើនទ្រទ្រង់ដោយមូលដ្ឋានកំណើនស្រដៀងទៅនឹងឆ្នាំ ២០១៨ និងថមថយមកត្រឹម ៦,៥% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកផលប៉ះពាល់នៃលទ្ធភាពក្នុងការដក EBA ដែលអាចនឹងដាក់សម្ពាធដល់ការនាំចេញរបស់កម្ពុជា ជាពិសេសលើផលិតផលកាត់ដេរ ទៅកាន់ទីផ្សារអឺរ៉ុប ។ ផ្អែកលើនិន្នាការខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៩ និង ២០២០ ត្រូវបានព្យាករដូចខាងក្រោម÷

**៩.** ***(ក). វិស័យកសិកម្ម*** ត្រូវបានរំពឹងថានឹងបន្តកំណើនយឺតក្នុងរង្វង់ ១,៦% ក្នុងឆ្នាំ២០១៩ និង ១,៧% ក្នុងឆ្នាំ ២០២០ ដោយសារការថមថយកំណើននៃអនុវិស័យដំណាំ ទោះបីអនុវិស័យនេសាទ និងចិញ្ចឹមសត្វនៅបន្តកំណើនខ្ពស់ជាងឆ្នាំកន្លងទៅបន្តិចក្តី ។

**១០.** ជាក់ស្តែង អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ១,៧% ក្នុងឆ្នាំទាំងពីរដោយសារការថមថយនៃកំណើនផលិតកម្មស្រូវ ដែលបណ្តាលមកពីភាពមានកម្រិតនៃការពង្រីកផ្ទៃដីដាំដុះ, ភាពមិនអំណោយផលនៃកត្តាអាកាសធាតុ(ឥទ្ធិពលបាតុភូតហួតហែងEl Niño) និងកំណើនយឺតនៃផលិតភាពដីនិងកម្លាំងពលកម្ម ។ ដោយឡែកផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្មត្រូវបានរំពឹងថានឹងបន្តសន្ទុះកំណើន ដោយសារការកើនឡើងនូវការវិនិយោគលើវិស័យកសិឧស្សាហកម្ម រួមមាន ការវិនិយោគរបស់វិស័យឯកជនលើការកែច្នៃផលិតផលកសិកម្ម ដូចជា ដំឡូងមី, ចេក និងស្វាយ ។ល។

**១១.** អនុវិស័យនេសាទអាចនឹងសម្រេចបានក្នុងអត្រា ២,២% ក្នុងឆ្នាំ ២០១៩ និង ២,៤% ក្នុងឆ្នាំ ២០២០ ដែលនឹងជំរុញខ្លាំងដោយអនុវិស័យវារីវប្បកម្ម តាមរយៈការកើនឡើងនូវការវិនិយោគពីវិស័យឯកជន (ទាំងខ្នាតតូច និងមធ្យម) និងការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ ។ កំណើននៃអនុវិស័យនេះ នឹងជួយប៉ះប៉ូវមួយផ្នែកដល់ការថមថយនៃអនុវិស័យដំណាំ ។

**១២.** ជាមួយគ្នានេះដែរ អនុវិស័យចិញ្ចឹមសត្វក៏ត្រូវបានព្យាករថានឹងមានកំណើនប្រសើរឡើងវិញ ក្នុងរង្វង់ ១,៣% និង ១,៤% ក្នុងឆ្នាំ ២០១៩ និង ២០២០ ដោយសារតែថ្លៃជ្រូករស់ត្រូវបានរំពឹងថានឹងបន្តកើនឡើងក្នុងឆ្នាំ ២០១៩ ដែលជំរុញដល់ការបង្កើនការចិញ្ចឹមជ្រូក ។ និន្នាការនេះ ស្របគ្នានឹងការកើនឡើងនៃការចិញ្ចឹមមាន់, គោ និងក្របី ផងដែរ ។

**១៣.** ទន្ទឹមនឹងនិន្នាការខាងលើ វិស័យកសិកម្មនៅតែជួបនូវបញ្ហាប្រឈមជារចនាសម្ព័ន្ធជាច្រើន ដែលត្រូវដោះស្រាយរួមមាន ÷ កំណើនផលិតភាពទាប (ទាំងដី និងពលកម្ម), ភាពមានកម្រិតនៃការវិនិយោគលើវិស័យ

តែថ្លៃកសិផល, ថ្លៃដើមផលិតកម្មខ្ពស់បើប្រៀបធៀបនឹងប្រទេសជិតខាង និងភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងសមត្ថភាពស្ថាប័ន ។ ជាមួយគ្នានេះ វិស័យនេះក៏ប្រឈមខ្ពស់នឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិទាំងឡាយដែលនឹងអាចកើតមានឡើង ។ ដូច្នេះ ដើម្បីឱ្យវិស័យកសិកម្មមានសន្ទុះកំណើនខ្ពស់ឡើងវិញ និងដើម្បីរួមចំណែកឱ្យកាន់តែប្រសើរដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០៣០ ដែលត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ, សមស្រប និងអាចអនុវត្តបាន ចាំបាច់ត្រូវបញ្ចប់ និងអនុវត្តដោយគ្រប់ភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព ។

**១៤.** ***(ខ). វិស័យឧស្សាហកម្ម*** នឹងបន្តរក្សាកំណើនរឹងមាំ ក្នុងអត្រាប្រចាំឆ្នាំ ១០,៧% ក្នុងឆ្នាំ ២០១៩ ។ ដោយឡែក ក្នុងឆ្នាំ ២០២០ វិស័យនេះត្រូវបានព្យាករថានឹងមានកំណើនថមថយមកត្រឹម ៨,៩% ដែលគាំទ្រដោយកំណើនខ្ពស់នៃវិស័យសំណង់ និងវិស័យឧស្សាហកម្មផ្សេងទៀត ខណៈដែលវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនទាប ។

**១៥.** វិស័យកាត់ដេរត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរក្នុងអត្រាប្រមាណ ៧,១% ក្នុងឆ្នាំ ២០១៩ និងថមថយមកត្រឹម ៣,៥% ក្នុងឆ្នាំ ២០២០ ។ កំណើនយឺតក្នុងឆ្នាំ ២០២០ នេះ គឺដោយសារការថមថយកំណើនសេដ្ឋកិច្ចសកលលោក ជាពិសេសការរំពឹងទុកផលប៉ះពាល់ដែលបណ្តាលមកពីការដក EBA ដោយសហភាពអឺរ៉ុប ដែលនឹងអាចដាក់សម្ពាធដល់ការនាំចេញផលិតផលកាត់ដេររបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប ដែលជាទីផ្សារនាំចេញដ៏សំខាន់មួយរបស់កម្ពុជា ។ ទោះបីជាយ៉ាងនេះក្តី កំណើននេះអាចសម្រេចទៅបានលុះត្រាតែមានកិច្ចខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាលក្នុងការត្រៀម និងអនុវត្តនូវវិធានការមុតស្រួច ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការដក EBA និងហានិភ័យផ្សេងៗទៀតដែលអាចកើតមានជាយថាហេតុ ព្រមទាំងស្តារនូវទំនុកចិត្តរបស់អ្នកវិនិយោគក្នុងវិស័យនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តបញ្ចុះថ្លៃអគ្គិសនី, ថ្លៃដឹកជញ្ជូន និងឡូជីស្ទីក ព្រមទាំងបន្តធ្វើកំណែទម្រង់ស្ថាប័ន ដើម្បីជំរុញកិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ក្នុងគោលដៅពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជាឱ្យកាន់តែប្រសើរឡើង ។

**១៦.** វិស័យសំណង់ ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងអត្រា ១៧,៣% និង ១៦,១% ក្នុងឆ្នាំ ២០១៩ និង ២០២០ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងសំណង់អគារលំនៅឋានដែលមានថ្លៃទាបនិងមធ្យម ព្រមទាំងសំណង់អគារពាណិជ្ជកម្ម ជំនួសឱ្យកំណើនយឺតនៃសំណង់អគារលំនៅឋានដែលមានថ្លៃខ្ពស់ ។ ការព្យាករនេះ គឺស្របតាមនិន្នាការកើនឡើងនៃគម្រោងវិនិយោគក្នុងឆ្នាំ ២០១៨ ជាពិសេសលើសំណង់ដែលទ្រទ្រង់វិស័យទេសចរណ៍ ដូចជាសណ្ឋាគារ, រមណីយដ្ឋាន និងកាស៊ីណូ ដែលមានការកើនឡើងរហូតដល់ ១៦,៧% ធៀបនឹងឆ្នាំ ២០១៧ ដែលស្មើនឹងទឹកប្រាក់ប្រមាណ ២ ០០០ លានដុល្លារអាមេរិក ។ ជាក់ស្តែង ការនាំចូលសម្ភារៈ និងឧបករណ៍សំណង់ក្នុងឆមាសទី ២ ឆ្នាំ ២០១៨ បានកើនឡើងរហូតដល់ ៦៥% ។ ជាមួយគ្នានេះដែរ **"កត្តាចិន"** ត្រូវបានមើលឃើញថានឹងនៅតែជាកត្តាជំរុញកំណើនខ្ពស់នៃវិស័យនេះ សម្រាប់រយៈពេលមធ្យមខាងមុខ ដែលឆ្លុះបញ្ចាំងតាមរយៈការបន្តសន្ទុះកំណើននៃសកម្មភាពសាងសង់នៅតំបន់មាត់សមុទ្រ ក៏ដូចជាតំបន់នៅតាមព្រំដែន ។ ទោះជាយ៉ាងនេះក្តី វិស័យនេះពឹងផ្អែកខ្លាំងលើទុនវិនិយោគខាងក្រៅ ដូច្នេះផលប៉ះពាល់អវិជ្ជមានពីសង្គ្រាម

ពាណិជ្ជកម្ម និងការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ (monetary tightening) របស់ប្រទេសរីកចម្រើនមួយចំនួន នឹងបង្កជាហានិភ័យដល់វិស័យសំណង់នៅកម្ពុជា ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តឃ្លាំមើលឱ្យបានដិតដល់ និងធ្វើការសិក្សាឱ្យបានស៊ីជម្រៅពីការវិវត្តនៃវិស័យសំណង់និងអចលនទ្រព្យនៅកម្ពុជា ដើម្បីដាក់ចេញគោលនយោបាយអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ក្នុងការបញ្ចៀសហានិភ័យដែលអាចកើតមាន ។

**១៧.** វិស័យឧស្សាហកម្មមិនមែនកាត់ដេរ ត្រូវបានព្យាករថានឹងបន្តកំណើនខ្ពស់ក្នុងរង្វង់ ១០,៥% ក្នុងឆ្នាំ ២០១៩ និង ១១,៥% ក្នុងឆ្នាំ ២០២០ ដោយសារការពង្រីកមូលដ្ឋានផលិតកម្មផលិតផលមិនមែនកាត់ដេរនៃវិនិយោគដែលមានស្រាប់ ទាំងក្នុងនិងក្រៅតំបន់សេដ្ឋកិច្ច, ការរំពឹងទុកនៃនិន្នាការផ្លាស់ប្តូរទីតាំងរបស់រោងចក្រមួយចំនួនពីចិនមកកម្ពុជា និងការបន្តការវិនិយោគពីជប៉ុន, និងការបន្តកើនឡើងនៃការផ្គត់ផ្គង់ថាមពលក្នុងស្រុក ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយគាំទ្រវិស័យឯកជន ជាពិសេសការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងការលើកកម្ពស់សហគ្រិនភាពជាដើម ។ ដោយឡែក ឧស្សាហកម្មមិនមែនកាត់ដេរនៅក្នុងស្រុក មានការប្រឈមខ្ពស់នឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន ដូចជា កង្វះវត្ថុធាតុដើមក្នុងស្រុក, ថ្លៃអគ្គិសនីនៅខ្ពស់, និងកង្វះខាតប្រភេទអាជីវកម្មធុនកណ្តាល (missing middles) ដើម្បីផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មធំៗ ។ ដើម្បីឱ្យវិស័យនេះអាចរួមចំណែកឱ្យអស់សក្តានុពលនៅក្នុងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលនឹងពន្លឿនការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងគោលនយោបាយគាំទ្រនានា សំដៅកាត់បន្ថយថ្លៃដើមផលិតកម្ម និងជំរុញឱ្យមានការវិនិយោគបន្ថែម ។

**១៨.** ***(គ). វិស័យសេវាកម្ម*** ត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ ក្នុងរង្វង់ប្រមាណ ៦,៧% ក្នុងឆ្នាំ ២០១៩ និង ៦,៤% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនៃកំណើនល្អប្រសើរនៃវិស័យលក់ដុំ-លក់រាយ, អចលនទ្រព្យ, សណ្ឋាគារ និងភោជនីយដ្ឋាន, និងដឹកជញ្ជូននិងគមនាគមន៍ ។

**១៩.** វិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរ ប្រហាក់ប្រហែលឆ្នាំ ២០១៨ ក្នុងអត្រា ៥,៦% ទាំងក្នុងឆ្នាំ ២០១៩ និង ២០២០ ស្របនឹងការរំពឹងទុកនៃការបន្តកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យសណ្ឋាគារ និងរមណីយដ្ឋាន និងកំណើនភ្ញៀវទេសចរជនជាតិចិន ។ ទន្ទឹមនេះ ភ្ញៀវទេសចរចិនត្រូវបានព្យាករថានឹងនៅបន្តកំណើនខ្ពស់ ដែលឆ្លុះបញ្ចាំងពីភាពជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវគោលនយោបាយទាក់ទាញភ្ញៀវទេសចរចិន ព្រមទាំងការពង្រីកជើងហោះហើរត្រង់ពីខេត្ត និងក្រុងមួយចំនួនក្នុងប្រទេសចិនមកកម្ពុជា ។ ដោយឡែក ភ្ញៀវទេសចរក្រៅពីជនជាតិចិន ត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះ ដែលជាបញ្ហាមួយគួរឱ្យបារម្ភ ដោយសារភាពមានកម្រិតនៃការទាក់ទាញភ្ញៀវទេសចរចំណាយខ្ពស់ផ្សេងទៀតមកកម្ពុជា ខណៈដែលនិន្នាការនេះមិនមានកើតឡើងក្នុងប្រទេសថៃ និងវៀតណាមទេ ។ បន្ថែមពីនេះ វិស័យទេសចរណ៍កម្ពុជានៅបន្តប្រឈមនឹងកង្វះខាតពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍, ភាពមានកម្រិតនៃសេវាទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរបវន្ត និងស្ថាប័ន ព្រមទាំងការខាតបង់ចំណូល ក៏ដូចជាតម្លៃបន្ថែមជារៀងរាល់ឆ្នាំ ដោយសារអវត្តមាននៃឧស្សាហកម្មនិងសេវាកម្មគាំទ្រ (backward linkages) ។ ក្នុងន័យនេះ អាជ្ញាធរពាក់ព័ន្ធនឹងចាត់វិធានការក្នុងការរៀបចំឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងតំបន់ទេសចរណ៍

ព្រមទាំងរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការរយៈពេលវែង ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ដោយផ្តោតលើការកែលម្អការតភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងស្ថាប័ន, ការធ្វើពិពិធកម្មគោលដៅនិងផលិតផលទេសចរណ៍ឱ្យបានឆាប់រហ័ស និងការកែលម្អសេវាទេសចរណ៍ឱ្យមានគុណភាពស្តង់ដារ ដើម្បីទាក់ទាញភ្ញៀវទេសចរចំណាយខ្ពស់ឱ្យមកទស្សនាកម្ពុជាបន្ថែមទៀត ។

**២០.** វិស័យលក់ដុំ-លក់រាយ ត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរក្នុងអត្រា ៦,៨% ទាំងក្នុងឆ្នាំ ២០១៩ និង ២០២០ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងនៃចំណូលរបស់ប្រជាជន គួបផ្សំនឹងការផ្លាស់ប្តូរឥរិយាបថចំណាយទៅរកការចាយខ្ពស់ ។ ក្រៅពីនេះ ការបន្តកើនឡើងការវិនិយោគលើការសាងសង់ផ្សារទំនើបធំៗក៏បានឆ្លុះបញ្ចាំងពីសុទិដ្ឋិនិយមរបស់អ្នកវិនិយោគមកលើការរីកចម្រើននៃវិស័យនេះ ។ ដោយឡែក ការរីកចម្រើននៃវិស័យលក់ដុំ-លក់រាយ គឺអាស្រ័យទាំងស្រុងទៅនឹងលទ្ធភាពស្វែងរកចំណូលរបស់ប្រជាជន ដែលដើរស្របគ្នានឹងនិន្នាការរីកចម្រើននៃវិស័យផ្សេងៗក្នុងសេដ្ឋកិច្ចជាតិ ។ យ៉ាងណាមិញ ការរីកចម្រើននៃវិស័យនេះក៏កើតឡើងទន្ទឹមគ្នានឹងក្តីបារម្ភចំពោះការកើនឡើងនៃការប្រើប្រាស់ឥណទានមិនចំគោលដៅរបស់ប្រជាពលរដ្ឋផងដែរ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបង្កើនចំណេះដឹងមូលដ្ឋានក្នុងវិស័យហិរញ្ញវត្ថុដល់ប្រជាជន ដើម្បីធានានិរន្តរភាពការងារ និងចំណូល ព្រមទាំងការប្រើប្រាស់ឥណទានឱ្យមានប្រសិទ្ធភាព ។

**២១.** វិស័យអចលនទ្រព្យ ត្រូវបានរំពឹងថានឹងបន្តមានកំណើនខ្ពស់ក្នុងរង្វង់ ៨,៨% ក្នុងឆ្នាំ ២០១៩ និង ៨,៥% ក្នុងឆ្នាំ ២០២០ ដែលស្របគ្នាទៅនឹងនិន្នាការនៃវិស័យសំណង់ ។ កំណើននៃវិស័យនេះនឹងត្រូវទ្រទ្រង់ដោយការកើនឡើងនៃសកម្មភាពទិញ-លក់សំណង់អគារដែលមានថ្លៃទាប និងមធ្យម ជំនួសឱ្យការថមថយនៃប្រតិបត្តិការទិញ-លក់លំនៅឋានដែលមានថ្លៃខ្ពស់ ដោយសារកំណើនខ្លាំងនៃការផ្គត់ផ្គង់ធៀបនឹងតម្រូវការ ។ ក្រៅពីនេះ ការកើនឡើងនៃសកម្មភាពទិញ-លក់អចលនទ្រព្យនៅក្រៅរាជធានីភ្នំពេញ ជាពិសេសតាមតំបន់មាត់សមុទ្រ និងច្រកព្រំដែននឹងជំរុញវិស័យនេះបន្ថែមទៀត ។ ដោយឡែក វិស័យនេះក៏ប្រឈមនឹងហានិភ័យដូចគ្នាទៅនឹងវិស័យសំណង់ ហើយការបន្តកំណើនខ្ពស់ជាប់ៗគ្នានៃវិស័យអចលនទ្រព្យ ក៏បង្កជាក្តីបារម្ភចំពោះលទ្ធភាពនៃការកើតមានវិបត្តិហិរញ្ញវត្ថុ ដោយសារ**ឥណទានផ្តល់ឱ្យវិស័យនេះក៏ស្ថិតក្នុងអត្រាកំណើនខ្ពស់** (ប្រមាណ ៣០%) ទោះបីជាមានការដាក់ចេញនូវគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នដោយធនាគារជាតិនាពេលកន្លងមកក៏ដោយ ។ ដូច្នេះ ការបន្តតាមដានវិស័យនេះប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ គឺជាការចាំបាច់ ដើម្បីបញ្ចៀសនូវវិបត្តិដែលអាចកើតមានជាយថាហេតុ ។

**២២.** វិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានព្យាករថាមានកំណើនល្អប្រសើរក្នុងរង្វង់អត្រា ៧,៩% និង ៧,៧% សម្រាប់ឆ្នាំ ២០១៩ និង ២០២០ ដោយសារការរំពឹងទុកនូវកំណើនល្អប្រសើរនៃសកម្មភាពដឹកជញ្ជូនក្នុងវិស័យសំខាន់ៗ និងភាពប្រសើរឡើងនៃវិស័យទូរគមនាគមន៍ ។ ភាពរឹងមាំនៃវិស័យកាត់ដេរ, សំណង់ និងសកម្មភាពទេសចរណ៍ នឹងធ្វើឱ្យសកម្មភាពដឹកជញ្ជូនកាន់តែមានភាពមមាញឹកជាងមុន ។ ទន្ទឹមនេះ ការបន្តកើនឡើងនៃអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត និងការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ នឹងជំរុញឱ្យវិស័យទូរគមនាគមន៍កាន់តែរីកចម្រើនជាងមុនក្នុងរយៈពេលមធ្យម ។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកនៅកម្ពុជានៅមានភាពទន់ខ្សោយ ហើយផែនការមេគ្រប់ជ្រុងជ្រោយទាំងពីរនៃវិស័យនេះ ក៏មិនទាន់បានបញ្ចប់ និងដាក់ឱ្យអនុវត្ត

នៅឡើយ ។ ជាមួយគ្នានេះ ថ្លៃសេវាអ៊ីនធឺណែត នៅមានកម្រិតខ្ពស់បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ ។ ទន្ទឹមនេះ វិស័យដឹកជញ្ជូន និងគមនាគមន៍ ក៏ប្រឈមនឹងហានិភ័យនៃការថមថយរបស់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចជាតិ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងពន្លឿនការរៀបចំ និងដាក់ចេញនូវផែនការមេគ្រប់ជ្រុងជ្រោយសម្រាប់អភិវឌ្ឍវិស័យដឹកជញ្ជូន ដើម្បីជំរុញដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឱ្យមានប្រសិទ្ធភាព និងចីរភាព ដែលគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិទាំងមូល ។

**តារាងទី១÷ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| | ២០១៨ ប. | ២០១៩ ប. | ២០២០ ព្យ. |
|---|---|---|---|
| កំណើន ផសស | ៧,៥% | ៧,១% | ៦,៥% |
| កសិកម្ម | ១,៦% | ១,៦% | ១,៧% |
| ដំណាំ | ១,៩% | ១,៧% | ១,៧% |
| ការចិញ្ចឹមសត្វ | ០,៤% | ១,៣% | ១,៤% |
| នេសាទ | ២,១% | ២,២% | ២,៤% |
| ព្រៃឈើ | -១,៤% | -១,៤% | -១,៤% |
| ឧស្សាហកម្ម | ១២,៣% | ១០,៧% | ៨,៩% |
| កាត់ដេរ | ១០,១% | ៧,១% | ៣,៥% |
| សំណង់ | ១៨,១% | ១៧,៣% | ១៦,១% |
| ឧស្សាហកម្មមិនមែនកាត់ដេរ | ១០,៣% | ១០,៥% | ១១,៥% |
| សេវាកម្ម | ៦,៥% | ៦,៧% | ៦,៤% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,៧% | ៥,៦% | ៥,៦% |
| លក់ដុំ-លក់រាយ | ៦,៦% | ៦,៨% | ៦,៨% |
| អចលនទ្រព្យ | ៨,៩% | ៨,៨% | ៨,៥% |
| ដឹកជញ្ជូន និងគមនាគមន៍ | ៨,១% | ៧,៩% | ៧,៧% |

ប្រភព÷ ការប៉ាន់ស្មាន និងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ មីនា ឆ្នាំ ២០១៩

**២៣.** *អត្រាអតិផរណា* ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតទាប ប្រមាណជា ២,៨% និង ២,៩% ក្នុងឆ្នាំ ២០១៩ និង ២០២០ ដោយសារការរំពឹងទុកនៃកំណើនយឺតនៃថ្លៃម្ហូបអាហារ និង ថ្លៃដឹកជញ្ជូន ។ ការរំពឹងទុកនៃកំណើនទាបនៃថ្លៃម្ហូបអាហារនេះ គឺស្របនឹងការរំពឹងទុកនៃការធ្លាក់ចុះថ្លៃប្រេង ក៏ដូចជាថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ ព្រមទាំងការបន្តទទួលបានផលជាផ្លែផ្កាពីការអនុវត្តវិធានការមួយចំនួន ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជានាពេលកន្លងមក ដូចជា÷ ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋាន, ការបង្កើនភាពប្រកួតប្រជែងក្នុងអាជីវកម្មសត្តឃាតដ្ឋាន, ការលុបភាស៊ីផ្សេងៗ និងកំណើននៃការផ្គត់ផ្គង់កសិផលក្នុងស្រុក ។

**២៤.** ***អត្រាប្ដូរប្រាក់*** រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាព ក្នុងឆ្នាំ ២០១៩ និង ២០២០ ពោលគឺស្ថិតក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ ។

**២៥.** ***ឱនភាពគណនីចរន្ត*** (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៦% និង ៩,៣% នៃ ផសស ក្នុងឆ្នាំ ២០១៩ និង ២០២០ ។ ការរួមតូចនៃឱនភាពគណនីចរន្តនេះ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកការបន្តកើនឡើងនៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងការថយចុះនៃឱនភាពសមតុល្យពាណិជ្ជកម្ម ដោយសារការថមថយនៃការនាំចូលវត្ថុធាតុដើមកាត់ដេរ ស្របនឹងកំណើនទាបនៃការនាំចេញផលិតផលកាត់ដេរ ។ ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ១១ ៥០៥ លានដុល្លារអាមេរិក និង ១៣ ០០៧ លានដុល្លារអាមេរិក ដែលធានាការនាំចូលឆ្នាំបន្ទាប់បាន ៥,៨ ខែ និង ៦,១ ខែ ។

**តារាងទី២÷ តារាងការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០១៨ ប. | ២០១៩ ប. | ២០២០ ព្យ. |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១៣ ០៤៨ | ១៤ ៦៨៩ | ១៥ ៦១៨ |
| ការនាំចូល ( លានដុល្លារអាមេរិក) | ១៨ ៥៩០ | ២០ ៥៥០ | ២២ ០១៨ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ២ ៦១៥ | ២ ៥៦២ | ២ ៧២៩ |
| ការនាំចេញ (%នៃ ផសស) | ៥៣,៥ | ៥៤,៨ | ៥៣,២ |
| ការនាំចូល (%នៃ ផសស) | ៧៦,៣ | ៧៦,៧ | ៧៥,០ |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -២២,៧ | -២១,៩ | -២១,៨ |
| សមតុល្យគណនីចរន្ត (%នៃ ផសស) | -១០,៧ | -៩,៦ | -៩,៣ |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | ៣ ១១៨ | ៣ ៦៦៦ | ៤ ៣២៨ |
| វិនិយោគផ្ទាល់ពីបរទេស (កំណើនប្រចាំឆ្នាំ) | ១៦,៦ | ១៧,៦ | ១៨,១ |

ប្រភព÷ ការប៉ាន់ស្មាន និងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ មីនា ឆ្នាំ ២០១៩

**២៦.** ក្នុងបរិបទនៃបញ្ហាប្រឈម និងហានិភ័យនានាដែលបានលើកឡើងខាងលើ ជាពិសេសលទ្ធភាពនៃការដក EBA, ដើម្បីបន្តកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងឯករាជ្យភាព រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការគោលនយោបាយគន្លឹះជាក់លាក់ចំនួន៤ ដូចជា÷ ក). ការស្រូបយកការប៉ះទង្គិច (shock absorption), ខ). ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ, គ). ការពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និង ឃ). ការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃស្ថាប័នសាធារណៈ ។

**២៧. (ក). ការស្រូបយកការប៉ះទង្គិច÷** បង្កើតការងារថ្មីដើម្បីប៉ះប៉ូវការងារដែលបាត់បង់, ជួយសម្រួលការផ្លាស់ប្ដូរការងារពីវិស័យកាត់ដេរទៅវិស័យផ្សេងទៀត និងបញ្ជូនពលករទៅក្រៅប្រទេស ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលជំនាញរយៈពេលខ្លី ។

- ***ការបង្កើតការងារ÷*** បង្កើតការវិនិយោគថ្មីៗក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស, ជំរុញសកម្មភាពអាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យម, បណ្តុះបណ្តាលជំនាញចាំបាច់រយៈពេលខ្លី និងអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម ។
- ***ការផ្លាស់ប្តូរការងារ និងការបញ្ជូនពលករទៅក្រៅប្រទេស÷*** ជួយសម្របសម្រួល និងផ្តល់សេវាប្រឹក្សាពីព័ត៌មានទីផ្សារការងារ ដើម្បីប្តូរការងារទៅរកវិស័យកសិកម្ម, ទេសចរណ៍, សំណង់ និងវិស័យផ្សេងៗទៀត ក៏ដូចជាខិតខំបង្កើនកូតាពលករទៅទីផ្សារប្រទេសមានស្រាប់ និងស្វែងរកប្រទេសថ្មីដែលមានសក្តានុពលខ្ពស់ ដូចជាប្រទេសជប៉ុន ជាដើម ។
- ***កម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ÷*** បណ្តុះបណ្តាលជំនាញបន្ថែមរយៈពេលខ្លី និងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែអំឡុងពេលហ្វឹកហាត់ ដើម្បីផ្តល់លទ្ធភាពឱ្យសិក្ខាកាមអាចបង្កើតអាជីវកម្មផ្ទាល់ខ្លួន ព្រមទាំងអាចផ្លាស់ប្តូរជំនាញទៅរកវិស័យថ្មី ឬវិស័យដែលប្រើបច្ចេកទេសខ្ពស់ជាងមុន ។

**២៨. (ខ). ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ÷** បន្តដោះស្រាយបញ្ហាជារចនាសម្ព័ន្ធមួយចំនួន ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា, ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យបានកាន់តែឆាប់រហ័ស និងពង្រឹងសមត្ថភាពស្ថាប័ន ។

- ***ការបង្កើនភាពប្រកួតប្រជែងកម្ពុជា÷*** បន្តជួយសម្រួលដល់ការកាត់បន្ថយថ្លៃដើម, ពេលវេលា និងបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម តាមរយៈការ១). ពង្រឹងវិស័យឡូជីស្ទិក ទាំងផ្នែករឹង និងទន់ ដោយបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយកម្រៃសេវាផ្សេងៗ; ២). បន្តកាត់បន្ថយថ្លៃអគ្គិសនី, រក្សាស្ថិរភាពនៃការផ្គត់ផ្គង់ និងបង្កើនលទ្ធភាព និងភាពងាយស្រួលក្នុងការទទួលបានការប្រើប្រាស់; ៣). បង្កើនការតភ្ជាប់វិស័យឌីជីថល; ៤). ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត; ៥). បណ្តុះបណ្តាលជំនាញទាំងរឹង និងទន់; ៦). កាត់បន្ថយជាអតិបរមានៃការិយាធិបតេយ្យ និង ៧). កាត់បន្ថយកម្រៃក្រៅផ្លូវការ និងរក្សាបាននូវបរិយាកាសធុរកិច្ចដែលអំណោយផលដល់ការធ្វើអាជីវកម្ម តាមរយៈការលើកកម្ពស់សេវាបង់ពន្ធ, ការកាត់បន្ថយការធ្វើសវនកម្មពន្ធដារត្រួតគ្នា និងការជំរុញឱ្យមានការប្រកួតប្រជែងដោយស្មើភាព ។
- ***ការជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច÷*** ជំរុញការធ្វើពិពិធកម្មផលិតកម្ម និងសេវាកម្ម ព្រមទាំងពិពិធកម្មទីផ្សារ ។
  - **ការជំរុញការធ្វើពិពិធកម្មផលិតកម្ម និងសេវាកម្ម÷** ១). អនុម័តច្បាប់វិនិយោគថ្មី, ច្បាប់ស្តីពីការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងច្បាប់ស្តីពីការប្រកួតប្រជែង; ២). បង្កើតផែនការមេអភិវឌ្ឍន៍ក្រុងព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង; ៣). បន្តលើកកម្ពស់សហគ្រិនភាព និងសហគ្រាសធុនតូច និងមធ្យម តាមរយៈការលើកទឹកចិត្តផ្នែកសារពើពន្ធ និង ៤). អភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ។
  - **ការជំរុញការធ្វើពិពិធកម្មទីផ្សារ÷** ស្វែងរកទីផ្សារក្រៅស្រុកបន្ថែម ទាំងពហុភាគី និងទ្វេភាគី តាមរយៈការពង្រីកទីផ្សារក្រៅប្រទេស ទៅក្នុងប្លុកពាណិជ្ជកម្មថ្មីៗដូចជា Cambodia-Eurasian

Economic Union Free Trade Agreement (Cambodia-EAEU FTA), ASEAN-European Union Free Trade Agreement (ASEAN-EU FTA), Comprehensive and Progressive Agreement for Trans-Pacific Partnership (CPTPP) និងពង្រឹងភាពជាដៃគូវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី (ចិន+១, ជប៉ុន+១, ថៃ+១ និងវៀតណាម+១ ជាដើម) ។

**២៩. (គ). ការពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ÷** ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញដោយការប្រើប្រាស់កញ្ចប់ថវិកាអន្តរាគមន៍ តាមរយៈការពង្រឹងការគៀរគរចំណូល និងការវិភាជ និងប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាព និងចំគោលដៅ ព្រមទាំងរក្សាស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីបញ្ចៀសនូវវិបត្តិជាយថាហេតុ ។

- ***ថវិកាជំរុញកំណើន÷*** ខិតខំគៀរគរចំណូលតាមរយៈការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ដោយមានការគិតបញ្ចូលនូវការផ្ដល់ឥណទានពន្ធ, ការលើកលែង ឬការអនុគ្រោះពន្ធ, ការលើកកម្ពស់ប្រសិទ្ធភាពចំណាយ ទាំងការវិភាជ និងការប្រើប្រាស់ថវិកា ព្រមទាំងការរឹតបន្តឹងចំណាយមិនចាំបាច់ (ការប្រជុំ និងបេសកកម្ម ជាដើម) ។
- ***ប្រភពហិរញ្ញប្បទាន÷*** កំណត់ប្រភពថវិកាសម្រាប់អន្តរាគមន៍ ដោយការប្រើប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល, ការបង្កើនកម្ចីពីបរទេស និង/ឬការវិភាជឡើងវិញនូវចំណាយមួយចំនួន ។
- ***គោលនយោបាយរូបិយវត្ថុ និងធនាគារ÷*** បន្តអនុវត្តវិធានការម៉ាក្រូប្រុងប្រយ័ត្ន និងវិធានការចាំបាច់ផ្សេងៗទៀត ដើម្បីបញ្ចៀសហានិភ័យក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលអាចកើតមានជាយថាហេតុ ។
- ***ស្ថិរភាពហិរញ្ញវត្ថុ÷*** រក្សាឱ្យបានប្រក្រតីភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ, ការផ្គត់ផ្គង់សាច់ប្រាក់ ឬឥណទាន, ស្ថិរភាពអត្រាប្តូរប្រាក់ និងស្ថិរភាពថ្លៃ ។

**៣០. (ឃ). ការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃស្ថាប័នសាធារណៈ÷** ដើម្បីអនុវត្តវិធានការអន្តរាគមន៍ឱ្យបានជោគជ័យ រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងបន្ថែមនូវអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន ដូចខាងក្រោម÷

- ***ពង្រឹងសមត្ថភាពស្ថាប័ន*** ក្នុងការដឹកនាំ និងការអនុវត្ត;
- ***បង្កើនប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន ឬមុខងារ*** តាមរយៈការធ្វើវិចារណកម្មមុខងារ និងភារកិច្ច ព្រមទាំងការលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង-ស្ថាប័ន;
- ***បង្កើនការអភិវឌ្ឍធនធានមនុស្ស*** ដោយផ្ដោតសំខាន់ទាំងបរិមាណ និងគុណភាព និង
- ***ផ្ដល់ការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលសាធារណៈ*** ដោយផ្អែកទៅលើសមិទ្ធិកម្ម ឬគុណាធិបតេយ្យ ។

**៣១.** *ជារួម ទោះបីកម្ពុជាអាចមានលទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់មកកំណើនខ្ពស់ក្នុងរង្វង់ ៦,៥% ក៏ដោយ ក៏ការសម្រេចបានកំណើននេះ ត្រូវអាស្រ័យទាំងស្រុងលើសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តវិធានការអន្តរាគមន៍ខាងលើឱ្យចេញលទ្ធផលជាផ្លែផ្កា ។*

## ៣. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**៣២.** ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ ដែលបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤**" មានគោលបំណង ដូចតទៅ÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងចីរភាព ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ និងហានិភ័យ ព្រមទាំងធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ; ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ; ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- ជំរុញប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ ដែលរួមមានការដាក់ឱ្យអនុវត្តសាកល្បងនូវក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២ និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២០-២០២២ ;
- ដាក់ឱ្យអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា;
- បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ក្នុងកម្រិតសមស្រប ដោយផ្អែកទៅលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ក្នុងគោលដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ;
- បន្តអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពសំដៅធានាបាននូវចីរភាពបំណុល;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ តាមរយៈការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន និងវិស័យថាមពល ក៏ដូចជាការតភ្ជាប់វិស័យឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី ៤;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ និង

- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម ។

**៣៣.** ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងដោយមានចរិតជាការគិតគូរវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការត្រៀមខ្លួនរួចជាស្រេច ដើម្បីឆ្លើយតបនឹងហានិភ័យទាំងឡាយ ដែលអាចកើតមានក្នុងសេដ្ឋកិច្ចកម្ពុជា ក្នុងគោលដៅរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ចីរភាពកំណើន និងការបង្កើតការងារជូនប្រជាពលរដ្ឋ ។ ក្នុងបរិបទនេះ កំណើនចំណូលនឹងមានល្បឿនយឺតជាងមុន ស្របនឹងការថមថយកំណើនសេដ្ឋកិច្ចជារួម ខណៈដែលចំណាយនឹងកើនឡើងខ្លាំង ដោយសារការអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ចាំបាច់នានា បន្ថែមលើចំណាយក្នុងស្ថានភាពសេដ្ឋកិច្ចធម្មតា ។

**៣៤.** ទោះជាយ៉ាងនេះក្តី សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ ការប្រមូលចំណូលអាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា ១). សន្ទុះកំណើនចំណូលសារពើពន្ធអាចប្រឈមនឹងកំណើនយឺត ដោយសារកម្រិតចំណូលបច្ចុប្បន្នបានខិតកៀកទៅនឹងពិដានចំណូលទៅហើយ ដោយផ្អែកលើបទពិសោធន៍នៃប្រទេសដែលមានសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងកម្ពុជា ។ ទន្ទឹមនេះ ចំណូលនេះ ក៏នឹងរំពឹងថានឹងអាចមានកំណើនយឺតជាងមុនស្របនឹងការថមថយកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងបរិបទនៃការដក EBA ក៏ដូចជា ការផ្តល់នូវការអនុគ្រោះពន្ធមួយចំនួន ដើម្បីជួយដល់ការអភិវឌ្ឍវិស័យឯកជន, ការជំរុញការវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស, ការគាំទ្រការអភិវឌ្ឍវិស័យអាទិភាពផ្សេងៗ និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគីជាដើម និង ២). ចំណូលមិនមែនសារពើពន្ធនៅមិនទាន់ប្រមូលឱ្យអស់សក្តានុពលនៅឡើយ ដោយសារអវត្តមាននៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ភាពមានកម្រិតនៃយន្តការក្នុងការកំណត់កម្រៃសេវាក្នុងវិស័យដែលជាប្រភពចំណូលសំខាន់ៗ, កង្វះការធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ និងភាពមានកម្រិតនៃការចរចាជាមួយភាគីពាក់ព័ន្ធលើការកំណត់ចំណូលពីសម្បទាន និងចំណូលពីការបែងចែកផលក្នុងប្រភពចំណូលដែលមានសក្តានុពលដូចជាវិស័យរ៉ែ និងថាមពល ។ល។

**៣៥.** ក្របខ័ណ្ឌចំណាយឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងដោយមានការគិតបញ្ចូលនូវកញ្ចប់ថវិកាអន្តរាគមន៍ដើម្បីឆ្លើយតបនឹងហានិភ័យនានាដែលអាចកើតឡើងនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដែលចំណាយអន្តរាគមន៍នេះ នឹងត្រូវឈរលើគោលការណ៍លើកកម្ពស់ប្រសិទ្ធភាពចំណាយទាំងក្នុងកម្រិតវិភាជន៍ និងអនុវត្ត ព្រមទាំងរឹតបន្តឹងចំណាយមិនចាំបាច់ផ្សេងៗ ។ បន្ថែមពីនេះ ប្រភពហិរញ្ញប្បទានសម្រាប់កញ្ចប់ថវិកាអន្តរាគមន៍នេះ អាចនឹងបានមកពីការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល, ការខ្ចីពីបរទេស និង/ឬការវិភាជចំណាយមួយចំនួនឡើងវិញ ។

**៣៦.** ដើម្បីឈានទៅសម្រេចគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ, រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈដូចខាងក្រោមនេះ÷

- ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០២០ ត្រូវគ្រោងសម្រេចឱ្យបាន ២២,៥២% នៃ ផសស ក្នុងនោះ ចំណូលចរន្តក្នុងទំហំ ២២,៣៦% នៃ ផសស និងចំណូលមូលធនក្នុងទំហំ 0,១៦% នៃ ផសស ។

ចំណូលចរន្តនឹងមានកំណើន ២៦,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ២០,៤៤% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,៩២% នៃ ផសស ។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ៩,៦៩% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៩,៧៨% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៨៨% នៃ ផសស ។

- ចំណាយសរុបថវិកាជាតិនៅឆ្នាំ ២០២០ នឹងកំណត់ក្នុងរង្វង់ ២៨,៤០% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៦,៤៨% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៨៣% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៩១% នៃ ផសស ។ ចំណាយចរន្តថវិកាជាតិត្រូវកំណត់ក្នុងកម្រិត ១៦,៧៥% នៃ ផសស ដែលក្នុងនោះ÷
  - ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៦,៣% នៃចំណាយចរន្តថវិកាជាតិ ត្រូវជា ៧,៧៥% នៃ ផសស ដែលត្រូវបានផ្តោតអាទិភាពលើការបង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ ។
  - ចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៣,៧% នៃចំណាយចរន្តថវិកាជាតិ ត្រូវជា ៩,០០% នៃ ផសស ដោយផ្តោតសំខាន់លើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម ។

**៣៧.** ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២០ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១១,៦៥% នៃ ផសស ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច ។

**៣៨.** ក្នុងនោះចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ២,២៥% នៃ ផសស និងមានការកើនឡើង ៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៩៩% នៃ ផសស និងមានកំណើន ៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៦១% នៃ ផសស និងមានកំណើន ២៥,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៥៨% នៃ ផសស និងមានកំណើន ៣៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ ។

**៣៩.** ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០២០ នឹងសម្រេចបានប្រមាណ ៥,៦១% នៃ ផសស និងឱនភាពថវិកាសរុបនឹងត្រូវឡើងដល់ ៥,៨៨%

នៃ ផសស ។ ក្នុងក្របខ័ណ្ឌនេះ ថវិកាឆ្នាំ ២០២០ មានចរិតជាការពង្រឹងវិន័យ និងប្រសិទ្ធភាពថវិកា តាមរយៈការរក្សាសមតុល្យថវិកា និងការផ្តោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយ ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ ។ *(សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៨-២០២២ ក្នុងឧបសម្ព័ន្ធ២ ភ្ជាប់មកជាមួយ)*

**៤០.** ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២០ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

**៣.១. វិធានការផ្នែកចំណូល**

**៤១.** វិធានការផ្នែកចំណូលសម្រាប់ឆ្នាំ ២០២០ ត្រូវបានរៀបចំដោយផ្អែកសំខាន់ទៅលើយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ក្នុងគោលបំណងធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលរដ្ឋ រួមមាន÷ ១). ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និង ២). ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលចំណូលមិនមែនសារពើពន្ធ ។ ដើម្បីសម្រេចបានគោលបំណងខាងលើ វិធានការកែទម្រង់ប្រព័ន្ធចំណូលរដ្ឋដែលមានលក្ខណៈទំនើបនឹងត្រូវបានដាក់ចេញដូចខាងក្រោម÷

**ក. វិធានការផ្នែកពន្ធដារ**

**៤២.** វិធានការគន្លឹះជាក់លាក់ សម្រាប់អនុវត្តក្នុងឆ្នាំ ២០២០ ក្នុងទិសដៅរក្សាកំណើនចំណូលពន្ធ និងឆ្លើយតបនឹងបញ្ហាប្រឈម រួមមាន÷

- ***បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា÷***
  - រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជី និងរៀបចំយន្តការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួងស្ថាប័នផ្សេងៗ;
  - បន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដែលបានពីលទ្ធផលនៃការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;
  - បញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ជាមួយវិស័យឯកជន អំពីការផ្តល់សេវាពន្ធដារ;
  - រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមានលក្ខណៈនវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកបង់ពន្ធ;
  - ជំរុញការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការចុះបញ្ជី (e-registration), ការដាក់លិខិតប្រកាសពន្ធ (e-filing), និងការបង់ប្រាក់ពន្ធ (e-payment) ឱ្យមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា តាមនិយាមអន្តរជាតិ;

- ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្មរួម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ;
- ដាក់ឱ្យអនុវត្តផែនការជាតិស្តីពីសវនកម្ម (national audit plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្មដោយផ្អែកលើកម្រិតហានិភ័យ (risk-based audit);
- បន្តជ្រើសរើសសហគ្រាសដែលមានបុគ្គលសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស;
- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
- ដាក់ឱ្យអនុវត្តតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និង
- ពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ដើម្បីធានាទំនុកចិត្តរបស់អ្នកបង់ពន្ធ ។

➢ ***បន្តពង្រឹងមុខងារគាំទ្រ ÷***

- បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីបង្កើនការប្រមូលចំណូលពន្ធ;
- បន្តសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងកែសម្រួលចំណុចខ្វះខាតនៃច្បាប់ស្តីពីសារពើពន្ធ;
- ពង្រឹងយន្តការតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា និងការកែប្រែគោលនយោបាយពន្ធដារនៃប្រទេសក្នុងតំបន់ និងសកលលោក;
- ដាក់ឱ្យអនុវត្តការរៀបចំឡើងវិញនូវដំណើរការការងារ និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា;
- បន្តពង្រឹងសមត្ថភាព និង ភាពជាអ្នកដឹកនាំរបស់អ្នកគ្រប់គ្រង និងមន្ត្រីជំនាញ តាមរយៈការបណ្តុះ-បណ្តាលទាំងក្នុង និងក្រៅប្រទេស;
- ដាក់ឱ្យអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងចាត់ចែងចំនួនមន្ត្រី និងបង្កើតនីតិវិធីប្រតិបត្តិសម្រាប់ការគ្រប់គ្រង (standard operating procedure) នៅគ្រប់អង្គភាពពន្ធដារ;
- ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីធានាតម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចផ្ទៃក្នុង;
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា និងបន្ថែមមុខងារថ្មីៗ ក្នុងប្រព័ន្ធនៃការគ្រប់គ្រងការចុះបញ្ជីសហគ្រាស, ការធ្វើសវនកម្ម, ការបង្វិលសង VAT, ការចុះបញ្ជីអចលនទ្រព្យ, ការបង់ប្រាក់ពន្ធ, ការតាមដាន និងវិភាគចំណូល, ការតាមដានឯកសារចេញ-ចូល និងការគ្រប់គ្រងធនធានមនុស្ស;

- រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ ១). help desk system ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព, ២). ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA system), ៣). ការគ្រប់គ្រងដំណើរការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ និង ៤). ការបញ្ចូលទិន្នន័យលិខិតប្រកាសប្រចាំខែ និងប្រចាំឆ្នាំ ដោយស្វ័យប្រវត្តិ (automated data capturing system) សម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ និង
- សិក្សា និងបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាព័ត៌មាន (security operation center - SOC) ។

**ខ. វិធានការផ្នែកគយ**

**៤៣.** វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២០ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (អ.គ.រ.) មាន ២ផ្នែក និងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម÷

➢ ***បន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម÷***

- កាត់បន្ថយ និងធ្វើសាមញ្ញកម្មនីតិវិធីគយ ឱ្យកាន់តែខ្លី និងងាយស្រួល តាមរយៈការធ្វើវិមជ្ឈការ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងកិច្ចសហប្រតិបត្តិការគយ;
- បន្តអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់តាមរយៈការផ្តល់ប្រព្រឹត្ត-កម្មពិសេសក្នុងការបំពេញបែបបទគយ និងត្រូវពិនិត្យលទ្ធភាពបង្កើនចំនួន best traders ហើយត្រូវចាប់ផ្តើមរៀបចំអនុវត្តយន្តការ AEO (authorized economic operator) ជាមួយប្រទេសជិតខាង ឬជាមួយប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា;
- កែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ, ប្រព័ន្ធ e-customs, ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
- ជំរុញអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិពេញលេញឱ្យបានឆាប់រហ័ស;
- កែលម្អវិធីសាស្ត្រនៃការកំណត់សូចនាករហានិភ័យដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រងហានិភ័យគយ (customs risk management database system);
- ពិនិត្យ និងវាយតម្លៃឡើងវិញលើ ១). បញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ (prohibited and restricted goods) និង ២). ភាពចាំបាច់នៃការប្រើប្រាស់លិខិតអនុញ្ញាតគយសម្រាប់ការនាំចេញ និងការនាំចូល ដើម្បីជួយសម្រួលបន្ទុករដ្ឋបាល ក៏ដូចជាចូលរួមចំណែកក្នុងការកាត់បន្ថយបន្ទុកចំណាយ និង
- បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ, ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

➢ ***បន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច៖***

- បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលពន្ធគយ ដែលបាត់បង់ពីការអនុវត្ត FTAs, ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និងការកើនឡើងនៃការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់;
- ចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១). ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករនាំចូល, និង ២). លើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យ ដើម្បីជាមូលដ្ឋានអាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;
- អនុវត្តសវនកម្មគយពេញលេញ (comprehensive custom audit) តាមរយៈការចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែង ជាជាងការត្រួតពិនិត្យតែលើឯកសារ;
- កំណត់ក្រុមហ៊ុនដែលត្រូវធ្វើសវនកម្មដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដើម្បីបង្កើនប្រសិទ្ធភាពសវនកម្ម;
- បញ្ចប់ និងអនុវត្តយុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy) និងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន (ICT strategy);
- ពិនិត្យឡើងវិញ កម្រិតពិន័យបទល្មើសគយ ដើម្បីធានាប្រសិទ្ធភាពការងារបង្ការបទល្មើស;
- កែលម្អ និងពង្រឹងយន្តការគ្រប់គ្រងព័ត៌មានបទល្មើសគយ ដោយបែងចែកឱ្យបានច្បាស់លាស់រវាងចំណូល និងប្រាក់ពិន័យដែលបានពីករណីបទល្មើសតូច និងធំ;
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយ ជាពិសេសការងាររបស់ការិយាល័យនាវាចរគយ;
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ និង
- ជំរុញលើកកម្ពស់អនុលោមភាពវិស័យឯកជន ដោយពង្រឹងក្រមសីលធម៌ដើងសារគយ, បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងដល់ធុរជនអំពីតម្លៃ និងកិត្តិយសនៃវប្បធម៌បង់ពន្ធស្អាតស្អំ និងផលវិបាកនៃអំពើគេចវេស និងបន្លំពន្ធ ។

**គ. វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ**

**៤៤.** ក្នុងទិសដៅបន្តកំណើន និងពង្រឹងប្រភពចំណូលសក្តានុពល បន្ថែមលើវឌ្ឍនភាពសម្រេចកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០២០ វិធានការគន្លឹះប្រចាំគ្រាដែលចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេលជាមួយយន្តការដែលមានស្រាប់;
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការស្ថាប័ន, ការបែងចែកភារកិច្ច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់, ការធ្វើសវនកម្ម និងអធិការកិច្ចលើអង្គភាពប្រមូលចំណូល, និងការដាក់ទោសទណ្ឌ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានពេញលេញនៅថ្នាក់ជាតិ និងឈានទៅពង្រីកប្រព័ន្ធនេះនៅថ្នាក់ក្រោមជាតិ;
- រៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយអនុវត្តសាកល្បងជាប្រព័ន្ធក្រៅបណ្តាញ (offline system) សម្រាប់ក្រសួង-ស្ថាប័ន, មន្ទីររាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់;
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ;
- ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ឱ្យស្របតាមការការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន;
- បន្តពិនិត្យ និងកែសម្រួលកម្រងសេវាសាធារណៈ ដើម្បីពិនិត្យលទ្ធភាពដាក់បញ្ចូលនូវប្រភពចំណូលថ្មីបន្ថែមទៀត ស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជា;
- រៀបចំប្រកាសអន្តរក្រសួង លើការចែករំលែកចំណូលសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល;
- ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចឱ្យអស់សក្តានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;

- បន្តសិក្សា និងរៀបចំជាបណ្ដើរៗនូវក្របខ័ណ្ឌគតិយុត្តថ្មីស្ដីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្រប តាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្ដែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្ដល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការអន្តរក្រសួង ដែលមានស្រាប់ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការកើតមានបំណុលថ្មី, ការតឹងទារបំណុល និងការលុបបំណុលកុំរ៉ៃដែលមិនអាចទារបាន;
- ពន្លឿនការអនុវត្តយន្តការកំណត់ និងបង់កម្រៃសេវា រួមមាន កម្រៃលេខទូរគមនាគមន៍, កម្រៃពីប្រេកង់ និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ;
- រៀបចំធ្វើវិសោធនកម្មច្បាប់ស្ដីពីវិស័យប្រៃសណីយ៍;
- ប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;
- បង្កើនសមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូល ដែលមានសក្ដានុពល ក្នុងវិស័យរ៉ែ និងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផល (equity share) ឱ្យមានប្រសិទ្ធភាព;
- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសិក្សាកែតម្រូវប្រកាសស្ដីពីការ គ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់អាជីវកម្ម និងគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ;
- បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ;
- ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្ដីពីការ គ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញ ការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;
- ជំរុញការអនុម័តច្បាប់ស្ដីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋាន គតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់;
- ពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលឱ្យអស់លទ្ធភាពពីអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ តាមរយៈ ការពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋាន សមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត;
- ធ្វើប្រតិភូកម្មការចេញលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាត តូច និងកម្រៃដែលទទួលបានពីលិខិតនេះ ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត;
- ពង្រឹងយន្តការត្រួតពិនិត្យ និងការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានជាធរមាន ដើម្បីធ្វើការផាកពិន័យ ចំពោះគ្រឹះស្ថានធានារ៉ាប់រង និងសោធន ដែលមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ;

- ដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មអចលនវត្ថុ ក្នុងគោលដៅជំរុញឱ្យក្រុមហ៊ុនប្រកបអាជីវកម្មគ្មានអាជ្ញាបណ្ណ មកស្នើសុំអាជ្ញាបណ្ណពីក្រសួងស្របតាមច្បាប់ជាធរមាន និង
- ដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងអាជីវកម្មពុះដីឡូតិ៍លក់ ។

### ៣.២. ទិដ្ឋានការផ្នែកចំណាយ

៤៥. ក្នុងក្របខ័ណ្ឌនៃគោលដៅទ្រទ្រង់ចលនការនៃការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យពាក់ព័ន្ធ ជាពិសេសលទ្ធភាពនៃការដក EBA ដោយសហភាពអឺរ៉ុប រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២០ ដូចខាងក្រោម÷

- គិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល ក្នុងករណីមានវិបត្តិផ្សេងៗ និងប្រធានស័ក្តិ;
- បន្តបង្កើនការឆ្លើយតបនៃថវិកា ទៅនឹងគោលនយោបាយអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់ ជាក់ស្តែង និងចំទិសដៅ ជាពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា;
- កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាពដែលទទួលបានគោលការណ៍ឯកភាពដោយក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាមី;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- បន្តគាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ តាមរយៈការបន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តចាស់ និងថ្មី;
- បន្តរក្សាអាទិភាព និងវិចារណកម្មចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក, កសិកម្ម, សហគ្រិនភាព និងសេដ្ឋកិច្ចឌីជីថល ជាដើម;
- ពង្រឹងការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ;
- ដាក់ឱ្យអនុវត្តអនុក្រឹត្យគោល ស្តីពីក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈក្នុងស្រុក រួមមាន ១). ការរៀបចំផែនការមេវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ក្រសួង-ស្ថាប័ន, ២). ការកំណត់គោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យគម្រោងដែលតម្រូវឱ្យមានការសិក្សាសមិទ្ធលទ្ធភាព និង ៣). ការធ្វើសមាហរណកម្មប្រតិទិននៃការរៀបចំផែនការគម្រោងវិនិយោគទៅនឹងប្រតិទិនរៀបចំថវិកា;

- បង្កើនទំហំ និងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែងកម្ពុជា និងបង្កើតការងារជូនប្រជាពលរដ្ឋ ក្នុងនោះជំរុញឱ្យមានការបញ្ចប់ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការមេតាមវិស័យសំខាន់ៗនេះ;
- ពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់វិធានការ, បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព និងតម្លាភាពនៃចំណាយសាធារណៈ;
- បន្តជំរុញការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ តាមរយៈការផ្ទេរសិទ្ធិអំណាចក្នុងការចាត់ចែងចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅក្រសួង-ស្ថាប័ន និងពីអង្គភាពហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នទៅអង្គភាពអនុវត្តការងារផ្ទាល់;
- បន្តកាត់បន្ថយនីតិវិធីចំណាយ ជាពិសេសបរិបទចំណាយថ្មីសម្រាប់ការអនុវត្តថវិកាកម្មវិធី តាមរយៈការប្តូរពីការត្រួតពិនិត្យមុនចំណាយ ទៅត្រួតពិនិត្យក្រោយចំណាយ និងដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅតាមក្រសួង-ស្ថាប័ន;
- ជំរុញការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុរយៈពេលខ្លី និងវែង ដើម្បីបន្ស៊ីមចំណែកក្នុងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងរាជធានី-ខេត្ត និងក្រុង-ស្រុក ជាពិសេសកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពី ការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះ ដែលបានគ្រោង រួមមាន÷
    - កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ១,៥ ប៊ីលាន ទៅ ២ ប៊ីលាន អេសដេអ៊ែរ ក្នុងមួយឆ្នាំ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា;
    - រក្សាអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស (present value of external public debt to GDP) ឱ្យស្ថិតក្រោម ៤០%;
    - បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ÷ ១). ការអនុវត្តប្រកាស ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់គ្រប់ដំណាក់កាល, ២). ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និង ៣). ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;

- o បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈការបន្តកៀរគរហិរញ្ញប្បទាន ពីដៃគូអភិវឌ្ឍន៍, វិស័យឯកជនក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, និងទីផ្សារមូលបត្រ និង
  - o បន្តពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាន និងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី÷ ១). ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, ២). វិស័យធនាគារ និងហិរញ្ញវត្ថុ និង ៣). ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- បន្តអនុវត្តវិធានការគន្លឹះ ក្នុងទិសដៅពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន÷
  - o ពង្រឹងគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី-ខេត្ត) ឱ្យបានទាន់ពេលវេលា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ;
  - o ដាក់រដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥ អនុវត្តថវិកាកម្មវិធី ដើម្បីធានាបាននូវភាពផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យចំគោលដៅអាទិភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា;
  - o ជំរុញការរៀបចំសៀវភៅថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី ឱ្យបានទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងប្រព័ន្ធ FMIS និង
  - o រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទប្បញ្ញត្តិ សម្រាប់ប្រតិបត្តិការចំណូល-ចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា÷ អនុក្រឹត្យស្តីពីការបន្ថែមធនធានចំណាយអភិវឌ្ឍន៍មូលដ្ឋានជូនរដ្ឋបាលឃុំ-សង្កាត់, អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបែងចែកចំណូលកម្រៃសេវារដ្ឋបាល នៃអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត, និងប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលចំណូលពីសេវាសាធារណៈជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ៤. សេចក្តីសន្និដ្ឋាន

**៤៦.** ជារួម ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃការគិតគូរត្រៀមខ្លួនរួចជាស្រេច ដើម្បីឆ្លើយតបនឹងហានិភ័យនៃការដក EBA ដោយសហភាពអឺរ៉ុប និងបានកំណត់ដាក់ចេញនូវវិធានការអន្តរាគមន៍សមស្របនិងទាន់ពេលវេលា ក្នុងគោលដៅបន្តរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចឱ្យបានក្នុងរង្វង់ ៦,៥% ជាមួយអត្រាអតិផរណាទាបដែលអាចគ្រប់គ្រងបានប្រមាណ ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ។ ជាមួយគ្នានេះផងដែរ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានរៀបចំឡើងស្របគ្នានឹងបរិការណ៍សេដ្ឋកិច្ចដូចបានរៀបរាប់ខាងលើ ដោយរាជរដ្ឋាភិបាលនឹង

ដាក់ចេញនូវគោលនយោបាយវិត្តារកម្មថវិកា ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងបង្កើតការងារជូនប្រជាពលរដ្ឋ ដោយដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីស្រូបយកការប៉ះទង្គិចរយៈពេលខ្លី, ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ, ពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃស្ថាប័នសាធារណៈ ។ ស្របនឹងការរំពឹងទុកនៃការថយចុះចំណូល អតិរេកចរន្តនឹងសម្រេចបានប្រមាណ ៥,៦១% នៃ ផសស ខណៈដែលឱនភាពថវិកាសរុបនឹងកើនឡើងរហូតដល់ ៥,៨៨% នៃ ផសស ។

**៤៧.** ដើម្បីធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងបរិបទនៃភាពមិនប្រាកដប្រជានៃការដក EBA រាជរដ្ឋាភិបាលនឹងមានការប្រុងប្រយ័ត្នខ្ពស់ជាងមុន ក្នុងការដាក់ចេញ និងអនុវត្តនូវវិធានការអន្តរាគមន៍ឱ្យបានទាន់ពេលវេលា និងប្រកបដោយផ្លែផ្កា ព្រមទាំងរក្សាឱ្យបាននូវទំនុកចិត្តវិនិយោគ ជាពិសេសក្នុងវិស័យជំរុញកំណើនសំខាន់ៗ ដើម្បីបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀត ។ រាជរដ្ឋាភិបាលក៏នឹងត្រូវ បន្តអនុវត្តការកែទម្រង់លើគ្រប់វិស័យឱ្យបានខ្លាំងក្លាជាងមុន និងប្រកបដោយឆន្ទៈនយោបាយខ្ពស់ ដើម្បីបង្កើនភាពប្រកួតប្រជែងកម្ពុជា និងជំរុញល្បឿនពិពិធកម្មសេដ្ឋកិច្ចឱ្យបានឆាប់រហ័ស ក្នុងគោលដៅពង្រឹងប្រភពកំណើនដែលមានស្រាប់ និងឈានទៅចាប់យកបន្ថែមទៀតនូវប្រភពកំណើនថ្មីៗដែលមានសក្តានុពល ។ ជាមួយគ្នានេះ គោលនយោបាយហិរញ្ញវត្ថុសាធារណៈក៏នឹងត្រូវពង្រឹងបន្ថែម ដោយផ្អែកលើគោលការណ៍បន្តកៀរគរចំណូលឱ្យស្របទៅនឹងបរិបទសេដ្ឋកិច្ច ព្រមទាំងបង្កើនប្រសិទ្ធភាពចំណាយទាំងក្នុងកម្រិតវិភាជន៍ និងប្រើប្រាស់ថវិកា ដោយ ឈរលើមូលដ្ឋានចាំបាច់ ចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់ ។

ឈឈឈ❋❋❋ឈឈឈ

**ឧបសម្ព័ន្ធ ១៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ២០១៦-២០២២**

| សូចនាករ | 2016 | 2017 | 2018 ប. | 2019 ប. | 2020 ព្យ. | 2021 ព្យ. | 2022 ព្យ. |
|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | **81,242** | **89,754** | **98,786** | **108,590** | **119,034** | **130,915** | **144,170** |
| ផសស សម្រាប់ម្នាក់ (ដុល្លារ) | 1,308 | 1,429 | 1,548 | 1,679 | 1,816 | 1,972 | 2,144 |
| កំណើន ផសស ពិត (%) | **7.0%** | **7.0%** | **7.5%** | **7.1%** | **6.5%** | **7.0%** | **7.0%** |
| អត្រាបរិត្តិផរណា ផសស (កំណើនប្រចាំឆ្នាំ) | 3.4% | 3.2% | 2.4% | 2.6% | 2.8% | 2.8% | 2.9% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 3.0% | 2.9% | 2.5% | 2.8% | 2.9% | 3.0% | 3.0% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | 4,056 | 4,045 | 4,053 | 4,054 | 4,054 | 4,054 | 4,054 |
| ការនាំចេញ (%នៃ ផសស) | 51.3% | 50.6% | 53.5% | 54.8% | 53.2% | 53.0% | 52.8% |
| ការនាំចូល (%នៃ ផសស) | 70.5% | 69.9% | 76.3% | 76.7% | 75.0% | 74.5% | 73.9% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -19.2% | -19.3% | -22.7% | -21.9% | -21.8% | -21.5% | -21.0% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផសស) | -8.4% | -8.0% | -10.7% | -9.6% | -9.3% | -8.8% | -8.3% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារ) | 6,731 | 8,758 | 10,052 | 11,505 | 13,007 | 14,484 | 15,973 |
| ចំនួនខែនៃការនាំចូល | 4.9 | 5.8 | 5.6 | 5.8 | 6.1 | 6.2 | 6.2 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០១៧) និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ឧបសម្ព័ន្ធ ២ : ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ**

**ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ: ២០១៨-២០២០**

*ផសស តាមថ្លៃចរន្តឆ្នាំ 2018 (ប៉ាន់ស្មាន)* 98,786

*ផសស តាមថ្លៃចរន្តឆ្នាំ 2019 (គម្រោង)* 108,590

*ផសស តាមថ្លៃចរន្តឆ្នាំ 2020 (គម្រោង)* 119,034

*ឯកតា÷ ប៊ីលានរៀល*

| ចំណូល- ចំណាយ | 2018 | | | | | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | បណ្ដោះអាសន្ន (*) | % ច្បាប់ | % អនុ. 2017 | % ផសស | ច្បាប់ហិ | កែតម្រូវព្យាករណ៍ចំណូល | ប្រែប្រួល កែ./ ច្ប. | កែ. ព្យ % ផសស | គម្រោង | % កែ.2019 | % ច្បាប់ 2019 | % ផសស |
| **ចំណូលក្នុងប្រទេសសរុប** | **18,587** | **21,892** | **117.8%** | **120.6%** | **22.16%** | **21,186** | **24,583** | **116.0%** | **22.64%** | **26,805** | **109.0%** | **126.5%** | **22.52%** |
| ចំណូលចរន្ត | 18,407 | 21,698 | 117.9% | 120.4% | 21.96% | 20,993 | 24,390 | 116.2% | 22.46% | 26,612 | 109.1% | 126.8% | 22.36% |
| ចំណូលមូលធន | 180 | 194 | 107.7% | 137.5% | 0.20% | 193 | 193 | 100.0% | 0.18% | 193 | 100.0% | 100.0% | 0.16% |
| **រដ្ឋបាល កណ្ដាល** | | | | | | | | | | | | | |
| ***ចំណូលចរន្ត*** | ***17,448*** | ***20,049*** | ***114.9%*** | ***118.2%*** | ***20.30%*** | ***19,593*** | ***22,419*** | ***114.4%*** | ***20.65%*** | ***24,325*** | ***108.5%*** | ***124.2%*** | ***20.44%*** |
| ចំណូលសារពើពន្ធ | 15,076 | 17,351 | 115.1% | 119.5% | 17.56% | 16,879 | 19,345 | 114.6% | 17.81% | 21,107 | 109.1% | 125.1% | 17.73% |
| ចំណូលមិនមែនសារពើពន្ធ | 2,372 | 2,698 | 113.7% | 110.4% | 2.73% | 2,714 | 3,075 | 113.3% | 2.83% | 3,218 | 104.7% | 118.6% | 2.70% |
| ***ចំណូលមូលធន*** | ***180*** | ***194*** | ***107.7%*** | ***137.5%*** | ***0.20%*** | ***193*** | ***193*** | ***100.0%*** | ***0.18%*** | ***193*** | ***100.1%*** | ***100.1%*** | ***0.16%*** |
| **រាជធានី-ខេត្ត** | **959** | **1,649** | **172.0%** | **156.8%** | **1.67%** | **1,400** | **1,970** | **140.7%** | **1.81%** | **2,286** | **116.0%** | **163.3%** | **1.92%** |
| ចំណូលសារពើពន្ធ | 910 | 1,603 | 176.0% | 158.7% | 1.62% | 1,352 | 1,918 | 141.9% | 1.77% | 2,070 | 108.0% | 153.2% | 1.74% |
| ចំណូលមិនមែនសារពើពន្ធ | 48 | 46 | 95.3% | 110.4% | 0.05% | 48 | 53 | 108.6% | 0.05% | 216 | 410.7% | 446.0% | 0.18% |
| **ចំណូលតាមអង្គភាព** | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 7,656 | 8,847 | 115.6% | 112.0% | 8.96% | 9,137 | 10,355 | 113.3% | 9.54% | 11,532 | 111.4% | 126.2% | 9.69% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 8,330 | 10,107 | 121.3% | 132.4% | 10.23% | 9,094 | 10,907 | 119.9% | 10.04% | 11,646 | 106.8% | 128.1% | 9.78% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,421 | 2,744 | 113.3% | 110.4% | 2.78% | 2,762 | 3,127 | 113.2% | 2.88% | 3,434 | 109.8% | 124.3% | 2.88% |

| ចំណូល-ចំណាយ | 2018 | | | | | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | បណ្ដោះអាសន្ន (*) | % ច្បាប់ | % អនុ. 2017 | %ផសស | ច្បាប់ហិ | កែតម្រូវព្យាករណ៍ចំណូល | ប្រែប្រួល កែ./ច្ប. | កែ.ព្យ % ផសស | គម្រោង | % កែ.2019 | % ច្បាប់ 2019 | % ផសស |
| **ចំណាយសរុប** | **24,375** | **24,095** | **98.9%** | **114.5%** | **24.39%** | **27,165** | **27,165** | **100.0%** | **25.02%** | **33,808** | **124.5%** | **124.5%** | **28.40%** |
| ចំណាយចរន្ត | 15,945 | 15,971 | 100.2% | 113.6% | 16.17% | 17,908 | 17,908 | 100.0% | 16.49% | 19,938 | 111.3% | 111.3% | 16.75% |
| ចំណាយមូលធន | 8,430 | 8,125 | 96.4% | 116.2% | 8.22% | 9,257 | 9,257 | 100.0% | 8.53% | 13,870 | 149.8% | 149.8% | 11.65% |
| **រដ្ឋបាល កណ្ដាល** | | | | | | | | | | | | | |
| ***ចំណាយ ចរន្ត*** | ***15,218*** | ***14,898*** | ***97.9%*** | ***112.6%*** | ***15.08%*** | ***16,827*** | ***16,827*** | ***100.0%*** | ***15.50%*** | ***18,109*** | ***107.6%*** | ***107.6%*** | ***15.21%*** |
| ***ចំណាយ មូលធន*** | ***7,473*** | ***7,168*** | ***95.9%*** | ***115.4%*** | ***7.26%*** | ***8,032*** | ***8,032*** | ***100.0%*** | ***7.40%*** | ***12,307*** | ***153.2%*** | ***153.2%*** | ***10.34%*** |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 2,926 | 2,926 | 100.0% | 146.8% | 2.96% | 2,708 | 2,708 | 100.0% | 2.49% | 6,254 | 230.9% | 230.9% | 5.25% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 4,547 | 4,243 | 93.3% | 100.5% | 4.29% | 5,324 | 5,324 | 100.0% | 4.90% | 6,053 | 113.7% | 113.7% | 5.09% |
| **រាជធានី ខេត្ត** | | | | | | | | | | | | | |
| ចំណាយចរន្ត | 1,465 | 1,810 | 123.6% | 123.9% | 1.83% | 1,880 | 1,880 | 100.0% | 1.73% | 2,914 | 155.0% | 155.0% | 2.45% |
| ចំណាយមូលធន | 220 | 220 | 100.0% | 102.3% | 0.22% | 320 | 320 | 100.0% | 0.29% | 457 | 143.0% | 143.0% | 0.38% |
| ***ឧបត្ថម្ភធនរាជធានី-ខេត្ត*** | ***738*** | ***738*** | ***100.0%*** | ***114.7%*** | ***0.75%*** | ***800*** | ***800*** | ***100.0%*** | ***0.74%*** | ***1,085*** | ***135.7%*** | ***135.7%*** | ***0.91%*** |
| **តុល្យភាព** | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 2,461 | 5,727 | 232.7% | 144.6% | 5.80% | 3,086 | 6,482 | 210.1% | 5.97% | 6,674 | 103.0% | 216.3% | 5.61% |
| ឱនភាពសរុប | (5,788) | (2,204) | 38.1% | 76.2% | -2.23% | (5,979) | (2,582) | 43.2% | -2.38% | (7,003) | 271.2% | 117.1% | -5.88% |
| **ហិរញ្ញប្បទានឱនភាព** | **5,788** | **2,204** | **38.1%** | **76.2%** | **2.23%** | **5,979** | **2,582** | **43.2%** | **2.38%** | **7,003** | **271.2%** | **117.1%** | **5.88%** |
| ក្នុងប្រទេស | 254 | (3,330) | -1312.2% | 150.5% | -3.37% | (501) | (3,898) | 778.1% | -3.59% | (406) | 10.4% | 81.0% | -0.34% |
| ក្រៅប្រទេស | 5,534 | 5,534 | 100.0% | 108.4% | 5.60% | 6,480 | 6,480 | 100.0% | 5.97% | 7,409 | 114.3% | 114.3% | 6.22% |
| ទ្រទ្រង់ថវិកាដោយដៃគូអភិវឌ្ឍន៍ | 250 | 250 | 100.0% | 78.7% | 0.25% | 250 | 250 | 100.0% | 0.23% | 250 | 100.0% | 100.0% | 0.21% |
| មូលធនក្រៅប្រទេស | 4,547 | 4,547 | 100.0% | 107.8% | 4.60% | 5,324 | 5,324 | 100.0% | 4.90% | 6,053 | 113.7% | 113.7% | 5.09% |
| ការទូទាត់ប្រាក់កម្ចី | 737 | 737 | 99.9% | 130.1% | 0.75% | 906 | 906 | 100.0% | 0.83% | 1,106 | 122.1% | 122.1% | 0.93% |

*(*) សម្គាល់ ÷ តួលេខបណ្ដោះអាសន្នគិតត្រឹមថ្ងៃ 05 កុម្ភៈ ឆ្នាំ 2019*

## ខ.១ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០១៩-២០២២

| ចំណូល/ចំណាយ | 2019 ច្បាប់ | 2019 កែតម្រូវ | 2020 ព្យ. | 2021 ព្យ. | 2022 ព្យ. |
|---|---|---|---|---|---|
| *ចំណាយបន្ទុកបុគ្គលិកជា % នៃ ចំណាយចរន្តសរុប* | *46.5%* | *46.5%* | *46.3%* | *45.4%* | *44.6%* |
| ប៊ីលានរៀល | | | | | |
| I. ចំណូលក្នុងស្រុក | 21,186 | 24,583 | 26,805 | 29,497 | 32,512 |
| ***I.1 ចំណូលចរន្តសរុប*** | ***20,993*** | ***24,390*** | ***26,612*** | ***29,275*** | ***32,276*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 9,094 | 10,907 | 11,646 | 12,600 | 13,645 |
| អគ្គនាយកដ្ឋានពន្ធដារ | 9,137 | 10,355 | 11,532 | 12,920 | 14,522 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,762 | 3,127 | 3,434 | 3,755 | 4,110 |
| II. ចំណាយសរុប | 27,165 | 27,165 | 33,808 | 36,151 | 39,500 |
| ***II.1 ចំណាយចរន្តសរុប*** | ***17,908*** | ***17,908*** | ***19,938*** | ***22,305*** | ***25,037*** |
| បន្ទុកបុគ្គលិក | 8,335 | 8,335 | 9,221 | 10,137 | 11,155 |
| បន្ទុកមិនមែនបុគ្គលិក | 9,572 | 9,572 | 10,716 | 12,168 | 13,883 |
| ***II.2 ចំណាយមូលធនសរុប*** | ***9,257*** | ***9,257*** | ***13,870*** | ***13,845*** | ***14,463*** |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | 3,028 | 3,028 | 6,711 | 6,230 | 6,310 |
| ទូទាត់ការខ្ចី | 906 | 906 | 1,106 | 1,211 | 1,415 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,324 | 5,324 | 6,053 | 6,404 | 6,738 |
| III. អតិរេកចរន្ត | 3,086 | 6,482 | 6,674 | 6,970 | 7,239 |
| IV. ឱនភាព/អតិរេកសរុប | (5,979) | (2,582) | (7,003) | (6,654) | (6,988) |
| កំណើនប្រចាំឆ្នាំ | 2019ច្បា./ប. | 2019កែ./ប. | 2020ព្យ./កែ | 2021ព្យ. | 2022ព្យ. |
| I. ចំណូលក្នុងស្រុក | -3.2% | 12.3% | 9.0% | 10.0% | 10.2% |
| ***I.1 ចំណូលចរន្តសរុប*** | ***-3.2%*** | ***12.4%*** | ***9.1%*** | ***10.0%*** | ***10.3%*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | -10.0% | 7.9% | 6.8% | 8.2% | 8.3% |
| អគ្គនាយកដ្ឋានពន្ធដារ | 3.3% | 17.1% | 11.4% | 12.0% | 12.4% |
| ចំណូលមិនមែនសារពើពន្ធសរុប | 0.7% | 14.0% | 9.8% | 9.3% | 9.5% |
| II. ចំណាយសរុប | 12.7% | 0.0% | 24.5% | 6.9% | 9.3% |
| ***II.1 ចំណាយចរន្តសរុប*** | ***12.1%*** | ***0.0%*** | ***11.3%*** | ***11.9%*** | ***12.2%*** |
| បន្ទុកបុគ្គលិក | 0.4% | 0.0% | 10.6% | 9.9% | 10.0% |
| បន្ទុកមិនមែនបុគ្គលិក | 24.8% | 0.0% | 12.0% | 13.5% | 14.1% |
| ***II.2 ចំណាយមូលធនសរុប*** | ***13.9%*** | ***0.0%*** | ***49.8%*** | ***-0.2%*** | ***4.5%*** |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | *-3.7%* | *0.0%* | *121.7%* | *-7.2%* | *1.3%* |
| ទូទាត់ការខ្ចី | 23.0% | 0.0% | 22.1% | 9.5% | 16.8% |
| ហិរញ្ញប្បទានក្រៅប្រទេស | 25.5% | 0.0% | 13.7% | 5.8% | 5.2% |
| ផលធៀបនឹង ផ.ស.ស | | | | | |
| I. ចំណូលក្នុងស្រុក | 19.51% | 22.64% | 22.52% | 22.53% | 22.55% |
| ***I.1 ចំណូលចរន្តសរុប*** | ***19.33%*** | ***22.46%*** | ***22.36%*** | ***22.36%*** | ***22.39%*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 8.37% | 10.04% | 9.78% | 9.62% | 9.46% |
| អគ្គនាយកដ្ឋានពន្ធដារ | 8.41% | 9.54% | 9.69% | 9.87% | 10.07% |
| ចំណូលមិនមែនសារពើពន្ធសរុប | 2.54% | 2.88% | 2.88% | 2.87% | 2.85% |
| II. ចំណាយសរុប | 25.02% | 25.02% | 28.40% | 27.61% | 27.40% |
| ***II.1 ចំណាយចរន្តសរុប*** | ***16.49%*** | ***16.49%*** | ***16.75%*** | ***17.04%*** | ***17.37%*** |
| បន្ទុកបុគ្គលិក | 7.68% | 7.68% | 7.75% | 7.74% | 7.74% |
| បន្ទុកមិនមែនបុគ្គលិក | 8.82% | 8.82% | 9.00% | 9.29% | 9.63% |
| ***II.2 ចំណាយមូលធនសរុប*** | ***8.53%*** | ***8.53%*** | ***11.65%*** | ***10.58%*** | ***10.03%*** |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | *2.79%* | *2.79%* | *5.64%* | *4.76%* | *4.38%* |
| ទូទាត់ការខ្ចី | 0.83% | 0.83% | 0.93% | 0.93% | 0.98% |
| ហិរញ្ញប្បទានក្រៅប្រទេស | 4.90% | 4.90% | 5.09% | 4.89% | 4.67% |
| III. អតិរេកចរន្ត | 2.84% | 5.97% | 5.61% | 5.32% | 5.02% |
| IV. ឱនភាព/អតិរេកសរុប | -5.51% | -2.38% | -5.88% | -5.08% | -4.85% |

*សម្គាល់ ÷ ចំណាយសោធននិវត្ត នឹងត្រូវកាត់ក្រោមចំណាយបៀវត្សចាប់ពីឆ្នាំ ២០១៩ តទៅ*

## ខ.២ ចំណាយតាមវិស័យរយៈពេលមធ្យម ២០១៩-២០២២

| ចំណាយតាមវិស័យ | 2019 ច្បាប់ | 2019 កែ. | 2020 ព្យ. | 2021 ព្យ. | 2022 ព្យ. |
|---|---|---|---|---|---|
| ប៊ីលានរៀល | | | | | |
| 1. ចំណាយ សរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | 27,165 | 27,165 | 33,808 | 36,151 | 39,500 |
| **1.1 ថ្នាក់ជាតិ** | **25,765** | **25,765** | **31,522** | **33,651** | **36,714** |
| ក.វិស័យរដ្ឋបាលទូទៅ | 2,464 | 2,464 | 2,675 | 2,768 | 2,901 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 17 | 17 | 148 | 127 | 140 |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,425 | 4,425 | 4,752 | 5,175 | 5,642 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 79 | 79 | 82 | 84 | 87 |
| គ.វិស័យសង្គមកិច្ច | 7,249 | 7,249 | 9,063 | 9,559 | 10,372 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 280 | 280 | 1,784 | 1,568 | 1,601 |
| ឃ.វិស័យសេដ្ឋកិច្ច | 6,620 | 6,620 | 9,018 | 9,256 | 9,767 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 846 | 846 | 1,976 | 1,808 | 1,921 |
| ង.ចំណាយផ្សេងៗ | 5,006 | 5,006 | 6,014 | 6,894 | 8,032 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 2,392 | 2,392 | 3,371 | 3,354 | 3,419 |
| **1.2 ថ្នាក់ក្រោមជាតិ** | **2,200** | **2,200** | **3,372** | **3,837** | **4,312** |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | 320 | 320 | 457 | 500 | 557 |
| 2. ចំណាយ សរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | 22,641 | 22,641 | 28,840 | 31,085 | 34,288 |
| **2.1 ថ្នាក់ជាតិ** | **20,441** | **20,441** | **25,469** | **27,248** | **29,976** |
| ក.វិស័យរដ្ឋបាលទូទៅ | 2,262 | 2,262 | 2,493 | 2,576 | 2,699 |
| *ក្នុងនោះ ចំណាយចរន្ត* | 2,246 | 2,246 | 2,346 | 2,448 | 2,559 |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,343 | 4,343 | 4,752 | 5,175 | 5,642 |
| *ក្នុងនោះ ចំណាយចរន្ត* | 4,264 | 4,264 | 4,670 | 5,091 | 5,555 |
| គ.វិស័យសង្គមកិច្ច | 6,477 | 6,477 | 8,639 | 9,111 | 9,900 |
| *ក្នុងនោះ ចំណាយចរន្ត* | 6,197 | 6,197 | 6,855 | 7,543 | 8,299 |
| ឃ.វិស័យសេដ្ឋកិច្ច | 2,353 | 2,353 | 3,570 | 3,493 | 3,703 |
| *ក្នុងនោះ ចំណាយចរន្ត* | 1,507 | 1,507 | 1,594 | 1,684 | 1,782 |
| ង.ចំណាយផ្សេងៗ | 5,006 | 5,006 | 6,014 | 6,894 | 8,032 |
| *ក្នុងនោះ ចំណាយចរន្ត* | 2,614 | 2,614 | 2,644 | 3,540 | 4,614 |
| 2.2 ថ្នាក់ក្រោមជាតិ | 2,200 | 2,200 | 3,372 | 3,837 | 4,312 |
| *ក្នុងនោះ ចំណាយចរន្ត* | 1,880 | 1,880 | 2,914 | 3,337 | 3,755 |

## ខ.២ ចំណាយតាមវិស័យរយៈពេលមធ្យម ២០១៩-២០២២

| កំណើនប្រចាំឆ្នាំ | | 2019កែ./ច្ប. | 2020ព្យ./ច្ប. | 2021ព្យ. | 2022ព្យ. |
|---|---|---|---|---|---|
| 1. ចំណាយ សរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | | 0.0% | 24.5% | 6.9% | 9.3% |
| **1.1 ថ្នាក់ជាតិ** | | **0.0%** | **22.3%** | **6.8%** | **9.1%** |
| ក.វិស័យរដ្ឋបាលទូទៅ | | 0.0% | 8.6% | 3.5% | 4.8% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *794.0%* | *-13.7%* | *10.2%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | | 0.0% | 7.4% | 8.9% | 9.0% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *3.0%* | *3.0%* | *3.0%* |
| គ.វិស័យសង្គមកិច្ច | | 0.0% | 25.0% | 5.5% | 8.5% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *537.2%* | *-12.1%* | *2.1%* |
| ឃ.វិស័យសេដ្ឋកិច្ច | | 0.0% | 36.2% | 2.6% | 5.5% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *133.6%* | *-8.5%* | *6.2%* |
| ង.ចំណាយផ្សេងៗ | | 0.0% | 20.1% | 14.6% | 16.5% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *40.9%* | *-0.5%* | *1.9%* |
| **1.2 ថ្នាក់ក្រោមជាតិ** | | **0.0%** | **53.3%** | **13.8%** | **12.4%** |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | | *0.0%* | *43.0%* | *9.3%* | *11.5%* |
| 2. ចំណាយ សរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | | 0.0% | 27.4% | 7.8% | 10.3% |
| **2.1 ថ្នាក់ជាតិ** | | **0.0%** | **24.6%** | **7.0%** | **10.0%** |
| ក.វិស័យរដ្ឋបាលទូទៅ | | 0.0% | 10.2% | 3.3% | 4.8% |
| *ក្នុងនោះ ចំណាយចរន្ត* | | *0.0%* | *4.4%* | *4.4%* | *4.5%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | | 0.0% | 9.4% | 8.9% | 9.0% |
| *ក្នុងនោះ ចំណាយចរន្ត* | | *0.0%* | *9.5%* | *9.0%* | *9.1%* |
| គ.វិស័យសង្គមកិច្ច | | 0.0% | 33.4% | 5.5% | 8.7% |
| *ក្នុងនោះ ចំណាយចរន្ត* | | *0.0%* | *10.6%* | *10.0%* | *10.0%* |
| ឃ.វិស័យសេដ្ឋកិច្ច | | 0.0% | 51.7% | -2.2% | 6.0% |
| *ក្នុងនោះ ចំណាយចរន្ត* | | *0.0%* | *5.8%* | *5.7%* | *5.8%* |
| ង.ចំណាយផ្សេងៗ | | 0.0% | 20.1% | 14.6% | 16.5% |
| *ក្នុងនោះ ចំណាយចរន្ត* | | *0.0%* | *1.1%* | *33.9%* | *30.3%* |
| **2.2 ថ្នាក់ក្រោមជាតិ** | | **0.0%** | **53.3%** | **13.8%** | **12.4%** |
| *ក្នុងនោះ ចំណាយចរន្ត* | | 0.0% | 55.0% | 14.5% | 12.5% |

## ខ.២ ចំណាយតាមវិស័យរយៈពេលមធ្យម ២០១៩-២០២២

| ផលធៀបនៃផ.ស.ស | 2019 ច្បាប់ | 2019 កែ. | 2020 ព្យ. | 2021 ព្យ. | 2022 ព្យ. |
|---|---|---|---|---|---|
| 1. ចំណាយ សរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | **25.02%** | **25.02%** | **28.40%** | **27.61%** | **27.40%** |
| **1.1 ថ្នាក់ជាតិ** | **23.73%** | **23.73%** | **26.48%** | **25.70%** | **25.47%** |
| ក.វិស័យរដ្ឋបាលទូទៅ | 2.27% | 2.27% | 2.25% | 2.11% | 2.01% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.02%* | *0.02%* | *0.12%* | *0.10%* | *0.10%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4.08% | 4.08% | 3.99% | 3.95% | 3.91% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.07%* | *0.07%* | *0.07%* | *0.06%* | *0.06%* |
| គ.វិស័យសង្គមកិច្ច | 6.68% | 6.68% | 7.61% | 7.30% | 7.19% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.26%* | *0.26%* | *1.50%* | *1.20%* | *1.11%* |
| ឃ.វិស័យសេដ្ឋកិច្ច | 6.10% | 6.10% | 7.58% | 7.07% | 6.77% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.78%* | *0.78%* | *1.66%* | *1.38%* | *1.33%* |
| ង.ចំណាយផ្សេងៗ | 4.61% | 4.61% | 5.05% | 5.27% | 5.57% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *2.20%* | *2.20%* | *2.83%* | *2.56%* | *2.37%* |
| **1.2 ថ្នាក់ក្រោមជាតិ** | **2.03%** | **2.03%** | **2.83%** | **2.93%** | **2.99%** |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.29%* | *0.29%* | *0.38%* | *0.38%* | *0.39%* |
| 2. ចំណាយ សរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទាន ក្រៅប្រទេស ) | 20.85% | 20.85% | 24.23% | 23.74% | 23.78% |
| **2.1 ថ្នាក់ជាតិ** | **18.82%** | **18.82%** | **21.40%** | **20.81%** | **20.79%** |
| ក.វិស័យរដ្ឋបាលទូទៅ | **2.08%** | **2.08%** | **2.09%** | **1.97%** | **1.87%** |
| *ក្នុងនោះ ចំណាយចរន្ត* | *2.07%* | *2.07%* | *1.97%* | *1.87%* | *1.77%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | **4.00%** | **4.00%** | **3.99%** | **3.95%** | **3.91%** |
| *ក្នុងនោះ ចំណាយចរន្ត* | *3.93%* | *3.93%* | *3.92%* | *3.89%* | *3.85%* |
| គ.វិស័យសង្គមកិច្ច | **5.96%** | **5.96%** | **7.26%** | **6.96%** | **6.87%** |
| *ក្នុងនោះ ចំណាយចរន្ត* | *5.71%* | *5.71%* | *5.76%* | *5.76%* | *5.76%* |
| ឃ.វិស័យសេដ្ឋកិច្ច | **2.17%** | **2.17%** | **3.00%** | **2.67%** | **2.57%** |
| *ក្នុងនោះ ចំណាយចរន្ត* | *1.39%* | *1.39%* | *1.34%* | *1.29%* | *1.24%* |
| ង.ចំណាយផ្សេងៗ | **4.61%** | **4.61%** | **5.05%** | **5.27%** | **5.57%** |
| *ក្នុងនោះ ចំណាយចរន្ត* | *2.41%* | *2.41%* | *2.22%* | *2.70%* | *3.20%* |
| **2.2 ថ្នាក់ក្រោមជាតិ** | **2.03%** | **2.03%** | **2.83%** | **2.93%** | **2.99%** |
| *ក្នុងនោះ ចំណាយចរន្ត* | *1.73%* | *1.73%* | *2.45%* | *2.55%* | *2.60%* |